Mulholland, J., *Medicine, magics and evil spirits*, Canberra, National Library of Australia, 1987.

Norodom, Ritharasy, *L'Évolution de la médecine au Cambodge*, Paris, Arnette L., 1929.

Pavie, A., *Mission Pavie, Indochine 1879-1895: géographie et voyages I*, Paris, Leroux éditeur, 1901.

Pelliot, P., « Le Fou-nan », *BEFEO*, 3, 1903, pp. 248-303.

Pelliot, Paul, *Mémoires sur les coutumes du Cambodge de Tcheou Ta-Kouan, version nouvelle suivie d'un commentaire inachevé*, Paris, Adrien-Maisonneuve, 1951.

Pichard, Pierre, François Lagirarde (eds.), *The Buddhist monastery*, Paris, EFEO, 2003.

Phou Sochea, *Kpuon khnāt khlaḥ nai saṃnaṅ' knuṅ pariveṇ vatt ārām [Treatise of some Measurements of Buildings in the Perimeter of Monasteries*], (in Khmer) Phnom Penh, Edition of the Buddhist Institute, 2003.

Ros Visoth, *"Vijjā bedy purāṇ" stī bī thnāṃ purāṇ niŵ rapīep byāpāl tām daṃnīeṃ damlāp' ["Ancient Medecine Science", about Ancient Drugs and Traditional Healing Practices]*, (in Khmer) Phnom Penh, B.A. dissertation (unpublished), Royal University of Fine Arts, Faculty of Archeology, 1995.

Sutthitham, Thada, "Monastic architecture in Northeastern Thailand", in *The Buddhist monastery*, Pierre Pichard & François Lagirarde (éds), Paris, EFEO, 2003, pp. 119-130.

Tcheou Ta-Kouan, *Mémoires sur les coutumes du Cambodge de Tcheou Ta-Kouan* (Traduit par Paul Pelliot), Paris, Adrien-Maisonneuve, 1951.

Van Esterik P.V., "To strenghten and refresh: Herbal therapy in Southeast Asia", *Soc Sci Med*, 27, 8, 1988, pp. 751-759.

Vidal, J.-E., *Paysages végétaux et plantes dans la Péninsule indochinoise*, Paris, Éditions Karthala, 1997.

Vidal, J.-E., G. Martel, S. Lewitz, « Notes ethnobotaniques sur quelques plantes en usage au Cambodge », *BEFEO*, tome LVI, 1969, pp. 171-232 + 6 pl.

លេខ ៦ គ.ស. ២០០៤ No. 6, 2004

# អំពីវាន [@] ១ ខ្សែ ក្រោមចំណងជើងថា «នេះតម្រាំរាប់ក្បួនថ្នាំម៉ែរោគឆ្វ័ ៤»

ដោយ ឆែម គាត រិទ្ធី
សាស្ត្រាចារ្យវិទ្យុព្យាបាល និង នរវិទ្យា សាកលវិទ្យាល័យអុន្តារីយោខាងលិច ក្រុងឡុណ្ដុន (កាណាដា)
និង មីស្ហែល បុទ្ធី អង់តែល្ម
គ្រូសន្និសីទ វិទ្យាស្ថានជាតិនៃភាសានិងអារ្យធម៌នៃបូព៌ាប្រទេស ក្រុងប៉ារីស (ប្រទេសបារាំង)

[@] កំណត់សម្គាល់របស់អ្នកនិពន្ធ៖ "វាន" ជាសាត្រា (សាស្ត្រា) ស្លឹករឹតខ្នាតតូចជាងសាត្រាស្លឹករឹតធម្មតា ។

***លោក ឡឺក្លែរ ជាអ្នកមុនគេ ដែលបានបោះពុម្ពផ្សាយអត្ថបទពេទ្យបុរាណខ្មែរ*** ចារលើសាត្រាស្លឹករឹតទាំងឡាយ ហើយបានធ្វើការសិក្សា អំពីវិជ្ជាពេទ្យបុរាណខ្មែរនេះ (ឡឺក្លែរ ១៨៩៤-១៨៩៥) ។ ការសិក្សាទាំងនេះ ប្រកបដោយសារៈសំខាន់ណាស់ និង មានឥទ្ធិពលខ្លាំងណាស់ទៅលើអ្នកស្រាវជ្រាវជំនាន់ក្រោយៗ ។ ក្រោយមក មានមនុស្សដទៃទៀតខ្លះ ដូចជាទ្រង់ នរោត្តម បុទ្ធរាសី (១៩២៩) ដែលបានទ្រង់លិខិតនិក្ខេបបទថ្នាក់បណ្ឌិត ស្ដីពីការវិវត្តនៃវិជ្ជាពេទ្យខ្មែរ, លោក ហ្វីលីយ៉ូហ្សាត់ (១៩៣៧) ដែលបានសរសេរសៀវភៅមួយអំពីក្បួនកុមារតន្ត្រ, លោក អាំង ជូលាន (១៩៩២) ដែលបានសរសេរអត្ថបទមួយ ជាសេចក្ដីផ្ដើមអំពីឥទ្ធិពលនៃវិជ្ជាពេទ្យឥណ្ឌាទៅលើប្រព័ន្ធពេទ្យខ្មែរ, និងលោក រស់ វិសុទ្ធ (១៩៩៥) ដែលបានសរសេរនិក្ខេបបទបញ្ចប់បរិញ្ញាបត្រស្ដីពីវិជ្ជាពេទ្យបុរាណ ។ នៅក្នុងអត្ថបទនេះ យើងខ្ញុំខំលើកយកខ្លឹមសាររបស់វានមួយខ្សែដែលបានរក្សានូវសភាពដ៏ល្អ ដែលយើងខ្ញុំបានប្រទះឃើញក្នុងបណ្ណសារដ្ឋាននៃសាលាបារាំងសែសចុងបូព៌ាប្រទេស ក្រុងប៉ារីស គឺសាត្រាលេខ ៩៨ ។ ខ្លឹមសារនៃសាត្រានេះទាក់ទងទៅនឹងវិជ្ជាពេទ្យបុរាណរបស់ខ្មែរ ដូចដែលយើងខ្ញុំនឹងអធិប្បាយខាងក្រោមនេះ ។ យើងខ្ញុំបានជ្រើសរើសវាននេះ ពីព្រោះមានទាំងការវិនិច្ឆ័យលក្ខណៈរោគ ទាំងការព្យាបាលរោគ គឺថា មានការពិនិត្យមើលជីពចរនិងឲ្យវិធីផ្សំថ្នាំ ។ ដើម្បីធ្វើការវិភាគនេះ យើងខ្ញុំបានប្រៀបធៀបអត្ថបទនិងប្រព័ន្ធវិជ្ជាពេទ្យបុរាណខ្មែរជាមួយនឹងអត្ថបទដែលមាននៅប្រទេសដទៃទៀតនៅអាស៊ីអាគ្នេយ៍ (ឡាដឺរម៉ាន ១៩៨៨: ១៤៧) ។ ការវិភាគនៅក្នុងបរិបទនៃអាស៊ីអាគ្នេយ៍នេះ មានសារៈសំខាន់ដើម្បីធ្វើការប៉ាន់ប្រមាណអំពីឥទ្ធិពលរបស់ឥណ្ឌាទៅលើវិធីកែរោគនៅអាស៊ីអាគ្នេយ៍ និងរបៀបដែលចំណេះដឹងអំពីវិជ្ជាពេទ្យបុរាណបានផ្ទេរមកដល់សម័យបច្ចុប្បន្ន ។

siksacakr 6khMichelFinal.qxd 28/08/2005 20:27 Page 110



## ក្បួនតម្រាវិជ្ជាពេទ្យបុរាណខ្មែរ

*ខ្មែរសម័យបុរាណធ្លាប់ចារអក្សរនៅលើផែនថ្ម លោហៈ សាត្រា ក្រាំង ស្បែកមនុស្ស (សាក់) ប៉ុន្តែកម្រធ្វើណាស់នៅលើស្បែកសត្វ ទោះបីជាលោក ជីវ តាក្វាន់ បានសរសេរទុកថា «លិខិតធម្មតានិងអត្ថបទទាំងអស់ ដូចជាឯកសារផ្លូវការជាដើមសុទ្ធតែសរសេរលើស្បែកសត្វប្រើស រមាំង ឬស្បែកដទៃទៀត ដែលគេយកមកហាលស្ងួតលាបពណ៌ខ្មៅ» (ប៉េល្លីយ៉ូត៍ ១៩៥១: ២០-២១, លី ធាមតេង ១៩៧៣: ៣៨) ។ គេចារសាត្រាស្លឹករឹតលើសន្លឹក ដែលធ្វើពីស្លឹកទ្រាំង ។ ក្រៅពីសាត្រា ក៏មានក្រាំង ដែលធ្វើពីសំបកមន ឬ សំបកស្នាយ ។ សាត្រានិងក្រាំង (ហ្គ្រាស៍លីយ៉េរ៍ ១៩២១: ៤) ដែលមានខ្លឹមសារសំខាន់ដូចជាក្បួន ហៅ គម្ពីរ (លី វូអុង ១៩៦៧: ១០៧) ។*

*អក្សរសិល្ប៍ខ្មែរចែកជាបីចំពូក (អូ ឈៀង ១៩៥៣:* VIII-X*) ។ ទី ១ គឺទេសន៍ ដែលស្តីពីព្រះពុទ្ធវាទ ។ ទី ២ គឺ ល្បែង ដែលជារឿងប្រលោមលោកតែងជាពាក្យកាព្យ ដែលអ្នកសូត្រសូត្រដើម្បីឲ្យអ្នកស្តាប់កម្សាន្តចិត្តសប្បាយរីករាយ ។ ក្នុងរឿងល្បែង មានប្រើពាក្យពេចន៍ពីរោះពីសា ប្រកបដោយន័យជ្រៅជ្រះ ស្តីពីជាតកទាំងឡាយ ឬ ពីរឿងរាមកេរ្តិ៍ ។ ទី ៣ គឺ ក្បួន ដែលជាអត្ថបទបច្ចេកទេសស្តីពីវិជ្ជាពេទ្យ វិធីផ្សំថ្នាំ ហោរាសាស្ត្រ ច្បាប់ក្រម ពង្សាវតារ គាថាមន្តអាគមព្យាករណ៍ ឬ ការបីឡាយាយីពីខ្មោចព្រាយបិសាច ។*

*គេរក្សាទុកសាត្រាខ្មែរក្នុងហិបឈើ ដែលខ្នុកម្រ័ក្សណ៍ពណ៌ខ្មៅឬក្រហម រចនានឹងទឹកមាសទៀតផង ។ ហិបនីមួយៗ អាចមានសាត្រាជាងមួយរយខ្សែ (ប៉ារី ១៩០១: ១៤) ។ ហិបទាំងនេះ គេទុកក្នុងហោត្រៃនៅតាមវត្ត (ជឺ ប៊ែណ៌ុង ២០០៣: ២១៧) ។ ពុំមាននរណាបានធ្វើការសិក្សាយ៉ាងល្អិតអំពីហោត្រៃនៅប្រទេសកម្ពុជា តែរបៀបសាងហោត្រៃក៏ដូចគ្នានឹងប្រទេសថៃ ហើយតាមលោកធាតា សុទ្ធិធម្ម (២០០៣: ១១៩) ជាសំណង់ធ្វើពីឈើ ដែលអាចមានដំបូលច្រើនថ្នាក់ សង់នៅកណ្តាលស្រះ ដើម្បីការពារកុំឲ្យកណ្តៀរស៊ីគម្ពីរសាត្រា ។ នៅក្នុងករណីខ្លះ ហោត្រៃ ក៏សម្រាប់លោកសង្ឃនិងសិស្សរបស់លោកមកគង់នៅ (បារ៉ូ ១៩៦៩: ៣៨) ។*

*ក្នុងចំណោមសាត្រាខ្មែរដែលតម្កល់ទុកក្នុងបណ្ណាល័យជាតិនៅប៉ារីស លោក អូ ឈៀង (១៩៥១) បានប្រទះឃើញនូវក្បួនតម្រាកែរោគជាច្រើន ហើយភាគច្រើនស្តីអំពីវិធីផ្សំថ្នាំ ។ មានសាត្រា ៥ ខ្សែ ដែលស្តីពីទ្រឹស្តីនិងរបៀបវិនិច្ឆ័យជីពចរ ក្រោមចំណងជើងថា ក្បួនជីពចរ គឺសាត្រាលេខ ១០៨, លេខ ១២៥-៣, លេខ ១៤៧-១ និងលេខ ១៦៨ អា-៣ ។ សាត្រាទាំងនេះរ៉ាយរ៉ាប់ពីចំពូកជីពចរទាំងឡាយ កន្លែងជីពចរស្ថិតនៅក្នុងរាងកាយតាមថ្ងៃទាំងអស់ក្នុងសប្តាហ៍ និងរបៀបប្រើជីពចរក្នុងការវិនិច្ឆ័យរោគ និងការព្យាករពីការវិវត្តនៃជម្ងឺ ។ នៅសាលាបារាំងសែសចុងបូព៌ាប្រទេសទីក្រុងប៉ារីស មានក្បួនវិជ្ជាពេទ្យចំនួនតិចជាង គឺ មានសាត្រាលេខ ៩៧ លេខ ៩៨ លេខ ៣១០ និងលេខ ៣៨១ ។ នៅក្នុងចំណោមនេះ សាត្រាលេខ ៩៧ មានសារៈសំខាន់ណាស់ ជាអត្ថបទខ្លីមួយស្តីពីកុមារតន្ត្រ គឺរបៀបកែរោគក្មេងៗ ដែលត្រូវខ្មោចបៀតបៀន (អាំង ជូលាន ១៩៩២) ។ សាត្រានេះជាគន្លឹះមួយនិងជាភស្តុតាងដ៏ជាក់លាក់បំផុតថា ទ្រឹស្តីវិជ្ជាពេទ្យបុរាណឥណ្ឌា បានបញ្ចូល*

ក្នុងវិជ្ជាពេទ្យខ្មែរ ។ ចំណែកឯឥទ្ធិពលរបស់ក្បួនតម្រាពេទ្យចិន វាពិបាកនឹងរកកស្តុតាងណាស់ ព្រោះយើងខ្វះឯកសារសរសេរ ។ ជាចុងក្រោយមក ការផ្លាស់ទីតាំងរបស់ប្រជាជនទាំងឡាយ និង ជំនួញដួញដូរជំសកម្មក្នុងជ្រោយឥណ្ឌូចិន ក៏គង់តែនាំឲ្យការប្រតិបត្តិក្នុងវិស័យពេទ្យ មានការយក ទៅយកមករវាងទំនៀមទម្លាប់កែរោគក្នុងប្រទេសនីមួយៗ នៃជ្រោយឥណ្ឌូចិននេះ (វ៉ាន់អេស្ដីរីក ១៩៨៨: ៧៥៥) ។

គេបានទុកអត្ថបទវិជ្ជាពេទ្យនៅអាស៊ីអាគ្នេយ៍ដូចជា "ប្រភពនៃគតិបណ្ឌិតមិនចេះប្រែប្រួល" ដូច្នេះ គេពុំសូវបានវាយសេចក្ដីនៃសាត្រាទាំងនេះ (ម៉ាក់កូឡេយ៍ ១៩៨៨: ៧៨០) ។ សេចក្ដីក្នុង សាត្រាទាំងនេះ ហាក់បីដូចជាសេចក្ដីសង្ខេបនៃវិធីផ្សំថ្នាំ របៀប"សៀវភៅធ្វើម្ហូប" (ម៉ាក់កូឡេយ៍ ១៩៨៨: ៧៨១) ។ តែការសំខាន់ជាងនេះទៅទៀត គឺថា គេទុកសាត្រាបុរាណដូចជាវត្ថុសក្តិសិទ្ធិជាទី សក្ការបូជា ។ ទេវតាមួយអង្គជានិមិត្តរូបនៃខ្លឹមសារក្នុងសាត្រាទាំងឡាយនេះ ។ នៅក្នុងប្រទេស កម្ពុជាសម័យបុរាណ រូបព្រះពោធិសត្វប្រជ្ញាបារមិតាតែងតែកាន់គម្ពីរ ១ ក្នុងព្រះហស្តស្តាំ (ហ្គែ ១៩៨២: ១១, ឃុន សាមេន ២០០២: ៤៥ និង ៥២) ។ ក្នុងប្រទេសខ្មែរក៏ដូចជាក្នុងប្រទេសឯ ទៀតនៅអាស៊ីអាគ្នេយ៍ដែរ គេចាត់ទុកផ្នែកទាំងឡាយនៃសាត្រាកែរោគ ដូចជារូបរបស់តួអក្សរទាំង ឡាយ សូរសម្លេងនៃអក្សរនោះ ពាក្យពេចន៍ សម្ភារៈសម្រាប់ចារ និងទឹកខ្មៅជាដើម ថា មាន អំណាចអាចព្យាបាលរោគបាន (ម៉ាក់កូឡេយ៍ ១៩៨៨: ៧៨១) ។ អក្សរមូលរបស់ខ្មែរ គេក៏ចាត់ទុក ថា មានបុទ្ធានុភាពខ្លាំងជាងពិធីឱមអាមដែលមានប្រើអក្សរផ្សេងពីអក្សរខ្មែរក្នុងជ្រោយឥណ្ឌូចិន (ហ្គូឡុំប៍ ១៩៨៤: ១១៤) ។ គេបានចារចម្លងក្បួនតម្រាពេទ្យបុរាណតៗគ្នា ។ អ្នកចារចម្លងខ្លះជាព្រះ សង្ឃ ខ្លះទៀតជាគ្រហស្ថដែលរស់នៅក្នុងវត្តអារាមឬក្បែរវត្តអារាម ។ នៅប្រទេសកម្ពុជា ក៏ដូចជា នៅប្រទេសដទៃទៀត ការចារចម្លងគម្ពីរសាត្រា ជាការធ្វើឲ្យអ្នកចារបានកុសលផលបុណ្យ (ឡាបាវ ២០០១: ២៥) ។ សព្វថ្ងៃនេះ គេបានតម្កល់ទុកសាត្រាជាច្រើនក្នុងបណ្ណាល័យក្នុងប្រទេសកម្ពុជានិង ក្រៅប្រទេសកម្ពុជា ។ គេបានយកមូលនិធិសាត្រាខ្មែរក្រុងភ្នំពេញទៅរក្សាទុកនៅសារមន្ទីរមនុស្ស នៅក្រុងប៉ារីស ឬ នៅសមាគមអាស៊ីក្រុងប៉ារីស (ឃីង ហុកឌី ២០០៣) ។ មានសាត្រាពេទ្យបុរាណ ខ្មែរដទៃទៀត ដែលគេបានយកទៅរក្សាទុកនៅបណ្ណាល័យជាតិនៅក្រុងបាងកក ហើយនៅក្នុងនេះ មានមួយចំនួនដែលគេបានបកប្រែជាភាសាសៀម (មឺល្ហូល្ដិន្ត ១៩៨៧: ១៦) ។ សាត្រាឯទៀតបាន បាត់ទៅលុះអវសាន ដោយសារគេយកទៅដុតជាមួយក្ដារមឈូសពេលបូជាសព ឬ គេបានកប់ក្នុង ចេតិយ ឬគេបានចោលទុកក្នុងកន្លែងណាមួយក្នុងវត្តដោយគ្មានការថែទាំ (ប៊ីហ្សូត៍ ១៩៧៦: III) ។

## តម្រាប់ក្បួនថ្នាំកែរោគទាំង ៤

សាត្រាលេខ ៩៨ ដែលយើងខ្ញុំបានជ្រើសរើសយកមកសិក្សានេះ គឺដោយហេតុថា មានទាំងវិធីផ្សំ ថ្នាំ ទាំងវិធីវិនិច្ឆ័យជីពចរ ។ មានចំណងជើងថា **នេះតម្រាប់ក្បួនថ្នាំមកែរោគទាំង ៤** (នេះ តម្រាប់ក្បួនថ្នាំកែរោគទាំង ៤) ។ ពាក្យថា តម្រាប់ជាពាក្យខ្មែរក្លាយមកពីកិរិយាស័ព្ទថា ត្រាប់ ។

siksacakr 6khMichelFinal.qxd 28/08/2005 20:29 Page 112



ក្នុងភាសាសៀម ពាក្យថា តម្រាប់ មានន័យដូចគ្នានឹងពាក្យថា តម្រា ។ អត្ថបទនេះ មុខតែផ្អែកលើទ្រឹស្តីនៃធាតុទាំង ៤ (ឆែម គាត រឹទ្ធី ២០០១) ។ សាត្រាលេខ ៩៨ នេះ ជារាន គឺជាសាត្រាស្ទឹករឹតមួយយ៉ាង ខ្នាតតូច ដែលគ្រូខ្មែរច្រើនតែប្រើ ។ ខ្សែលេខ ៩៨ នេះ មាន ១៦ សន្លឹក ទទឹង ៥,៤ ស.ម. បណ្តោយ ១៩,២ ស.ម. ។ សន្លឹកនីមួយៗ ចារទាំងសងខាង លើកលែងតែសន្លឹកទី ១ ដែលមានចារតែម្ខាង គឺមានចារចំណងជើង និងសន្លឹកទី ១៥ ដែលមានចារតែអក្សរ ណ ជាអង្គា ។ សន្លឹកទី ១៦ គ្មានចារអ្វីទាំងអស់ ។ ទំព័រនីមួយៗ មានចារអក្សរ ៥ បន្ទាត់ លើកលែងតែទំព័រចុងក្រោយបង្អស់ដែលមានតែ ៣ បន្ទាត់ ។ អក្សរចារ គឺ អក្សរមូល ។ តែតួអក្សរខ្លះសរសេរបែបអក្សរជ្រៀង ដូចជាតួអក្សរ វ និងជើង ន ជាដើម ដែលសរសេរជារូបអក្សរជ្រៀងវិញ ។ តាមទម្លាប់ មានចារអង្កាតែលើខ្នងសន្លឹក (គឺលើទំព័រទី ២ នៃសន្លឹកនីមួយៗ) ។ អង្កានេះជាអក្សរតាមលំដាប់ព្យញ្ជនៈ÷ ក ខ គ ឃ ដល់ ណ ។ អក្ខរាវិរុទ្ធ គឺជាអក្ខរាវិរុទ្ធដែលគេប្រើនៅចុងសតវត្សរ៍ទី ១៩ និងដើម ស.វ. ទី ២០ ។ ព្យញ្ជនៈ ត សម្រាប់កត់ទាំងអក្សរ ត ទាំងអក្សរ ដ ។ តួ គ និង តួ ត មានរូបដូចគ្នា អាចច្រឡំបាន ។ តួ ង និង តួ ដ ក៏មានរូបដូចគ្នាដែរ ។ ស្រៈសរសេរយ៉ាងមិនហ្មត់ចត់សោះឡើយ ។ អក្ខរាវិរុទ្ធពាក្យទាំងឡាយ មិនទៀងទាត់សោះ ។ តាមទម្លាប់នៅជំនាន់នោះ ជើងព្យញ្ជនៈច្រើនសម្រាប់កត់តួព្យញ្ជនៈប្រកប ។

រានខ្សែនេះអាចបែងចែកជាផ្នែកៗ បាន ។ ការណ៍គួរឲ្យឆ្ងល់ គ្មានផ្នែកមួយណា ដែលមានការពាក់ព័ន្ធនឹងចំណងជើង ។ ដូចសាត្រាឥណ្ឌាដែរ របៀបរៀបរៀងអត្ថបទពុំមានលំដាប់លំដោយសមហេតុសមផល ។ គេបានសង្កត់ធ្ងន់ទៅលើការពាក់ព័ន្ធរវាងលោកធាតុ សរីរៈ និងជម្ងឺ ព្រមទាំងព្យាករណ៍ពីការវិវត្តនៃជម្ងឺទាំងឡាយ និងវិធីព្យាបាលដែរ (លីយ៉េតារដ៍ ១៨៥៨: ៣៦) ។ ផ្នែកទី ១ មាន ៣ ទំព័រ ទាក់ទងនឹងជីពចរ យកជាវិធីវិនិច្ឆ័យរោគ ដោយមានការពិព័ណ៌នានូវបច្ចេកទេស និងរបៀបធ្វើតាមថ្ងៃក្នុងសប្តាហ៍ ។ ក្នុងផ្នែកទី ១ នេះ មានឃ្លាមួយចំនួនតែងជាបទកាកគតិ គឺចាប់ពីទំព័រទី ៤ បន្ទាត់ទី ៣ «ចាប័ចរ៍នេះឯង អាចារ៍សំម្តែង» ដល់ទំព័រទី ៧ បន្ទាត់ទី ២ «ឥតមានទុកក្បែ ចាប័ចរ៍នោះនៃ ចែងច់បម្ទេះហោង» ។ ផ្នែកទី ២ មាន ១៩ ទំព័រ ស្តីពីរុក្ខជាតិយកមកផ្សំជាថ្នាំ, ស្តីពីការកែរោគរបស់ថ្នាំទាំងនេះ និងពីពេលាល្អសម្រាប់ប្រើថ្នាំទាំងនេះ ។ ផ្នែកក្រោយបង្អស់រាយរាប់ពីរោគមួយ គឺ រោគហឺត ។ របៀបរៀបរៀងអត្ថបទនេះ គ្មានភាគស្មើគ្នា ។ ការផ្សំឱសថនីមួយៗ នៅតៗគ្នា ដោយគ្មានលំដាប់សមហេតុផល ។ ការផ្សំថ្នាំនីមួយៗ ជាកំណត់ហេតុ ដែលពុំមានការពាក់ព័ន្ធជាមួយនឹងការផ្សំថ្នាំដទៃទៀត ។ សម្រាប់វិធីផ្សំថ្នាំនីមួយៗ មានឲ្យឈ្មោះជម្ងឺឬសញ្ញារបស់ជម្ងឺ រួចមានឲ្យឈ្មោះរបស់រុក្ខជាតិទាំងឡាយ និងរបៀបផ្សំនិងធ្វើថ្នាំ ហើយជាចុងក្រោយបំផុតគឺរបៀបយកថ្នាំនេះឲ្យជា (ផឹក, លេប, លាប ។ល។) ។ របៀបរៀបរាប់យ៉ាងនេះ ឃើញមានក្នុងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ឯទៀតដែរ (ប៊្រុន និង ស្ទ្លម៉ាហ៊ឺរ ១៩៤៤: ៤៤) ។ នៅក្នុងក្បួនកែរោគទាំង ៤ នេះ គ្រឿងផ្សំភាគច្រើនជារុក្ខជាតិ ។ សត្វ ឬ រ៉ែលោហៈ យកមកធ្វើជាគ្រឿងផ្សំ មានតិចតួចនៅក្នុងក្បួននេះ ។

siksacakr 6khMichelFinal.qxd 28/08/2005 20:33 Page 113



នៅអាស៊ីអាគ្នេយ៍ ថ្នាំសត្វវេជ្ជពីរុក្ខជាតិ មានតួនាទី ២ គឺ កែរោគ និង ធ្វើឲ្យសុខភាពនៅតែបរិបូណ៌ (វ៉ាន់អេស្ដីរីក ១៩៨៨: ៧៥១) ។

ដូចនៅក្នុងប្រទេសឯទៀតនៅអាស៊ីអាគ្នេយ៍ដែរ ចំណេះដឹងអំពីវិជ្ជាពេទ្យបុរាណ ចម្លងទៅតាមរបៀបពីរយ៉ាង គឺពីមាត់មួយទៅមាត់មួយ និងតាមរយៈឯកសារសរសេរ ។ ឯកសារសរសេរ គឺដូចជា «[សៀវភៅធ្វើម្ហូប ដែលធ្វើឲ្យចំណេះដឹងនេះ គ្មានបន្លាញអ្វីពីគ្រូ ហើយធ្វើឲ្យឯកសារនេះមានលក្ខណៈជាទូទៅ]» ។ រីឯការផ្ទេរចំណេះដឹងពីមាត់មួយទៅមាត់មួយ «[ជួយឲ្យសិស្សចង់ចេះយ៉ាងជ្រៅជ្រះ ដោយសិស្សចូលរួមក្នុងការផ្សំថ្នាំ]» (វ៉ាន់អេស្ដីរីក ១៩៨៨: ៧៥៧) ។

នៅតទៅនេះ យើងខ្ញុំសូមជូននូវក្បួននេះជាពីរយ៉ាង ។ ទី ១ គឺសរសេរតាមអក្ខរាវិរុទ្ធច្បាប់ដើមទាំងស្រុង តែយើងខ្ញុំបានចម្លងជាអក្សរជ្រៀង មិនមែនជាអក្សរមូល ដើម្បីឲ្យងាយអាន ។ ទី ២ យើងខ្ញុំបានកត់អត្ថបទនេះ ដោយសរសេរតាមអក្ខរាវិរុទ្ធរបស់វចនានុក្រមខ្មែរនៃពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពគ្រាទី ៥ ព.ស. ២៥១១-២៥១២ គ.ស. ១៩៦៧-១៩៦៨ ។

## អត្ថបទដើមដោយរក្សាទុកនូវអក្ខរាវិរុទ្ធដើម

**[ទំព័រ ១]** នេះតម្រាំរាប័ក្បួន ថ្នាំមកែរោគទ្វា ៤ **[ទំព័រ ២]** [ទំព័រទទេ] **[ទំព័រ ៣]** **[១]** ១៑៕៚ ថ្ងៃ ១ នៅក្បាល ថ្ងៃ ២ នៅថ្ងាស ថ្ងៃ ៣ នៅច្រ **[២]** មោះ ថ្ងៃ ៤ នៅមុក ៈ ថ្ងៃ ៥ នៅពោះ ថ្ងៃ ៦ **[៣]** នៅផ្ចិត ថ្ងៃ ៧ នៅអស្សទ្វាខ្លួន ៕ នេះចាប័ចស្រើ **[៤]** ១៑៕៚ ថ្ងៃ ១ ចាប័ចរ៍នៅក្បា ល ថ្ងៃ ២ ចាប័ចរ៍នៅ **[៥]** អន្តាត ថ្ងៃ ៣ ចាប័ចរ៍នៅក្រចក ថ្ងៃ ៤ ចាប័ចរ៍ **[ទំព័រ ៤]** **ក៍** **[១]** នៅពោះស់ពូសេ៉ច ថ្ងៃ ៥ ចាប័ចរ៍នៅតែ ថ្ងៃ ៦ ចាប័ច **[២]** នៅលិន ថ្ងៃ ៧ ចាប័ចរ៍ នៅប្អាដ្ឋិង ៕ នេះឈ្មោះ **[៣]** ចាប័ចរ៍ប្រោស ៕ ចាប័ចរ៍ នេះឯង អាចារ៍សំម្តែង **[៤]** ទ្វាស់ពូទេវា ហៅចាប័ ចរ៍ឆ្នាំមឱ្យថ្នាំគ្រុបគ្នា **[៥]** ស់ពូនៃអាត្មា មុកគួរ៍ឱ្យតឹង ។ ប្តូរបស់ពូថ្ងៃ កេិត **[ទំព័រ ៥]** **[១]** ក្បាធទីទៃ ហេិមហល្វកន្ទង ជុំម្ងៃឈើហធ្មុន លុះ **[២]** ពុនផ្សិង ២ ប្រេិពែត្យ ផងតឹង ឱ្យចំ្នាបន្ទុះ ។ **[៣]** បេិហពែត្យផងមេិល ឱ្យ ចៀសតំម្នើរ៍ នៃចាប័ចរ៍ **[៤]** នោះ ចាប័ចរ៍នៅផ្ចិត ពោះ បេិហគិតបន្ទុះ ៈ **[៥]** លេិហចាប័ចរ៍នោះ កេិតទេវ្យពុំជា ស្មេិហយកថ្នាំមព្យិ **[ទំព័រ ៦]** **ខ** **[១]** មកប្រកឱ្យផ្ស ឱ្យខ្សែជុន្មា ជុំម្ងៃរីងធ្មុន លុនពុនក្តាត **[២]** ណា បង្កេិតទោស្សា ៈ ខុសក្រៃវិញហោង ៕ **[៣]** ៕ រីថ្ងៃទ្វាប៊ីប្រហស្សំតី ចន្ទអង្គាផង ប្រេិហឱ្យផិក **[៤]** ថ្នាំម បងខំមភ្ញេិងផង ៈ ត្នាគ្បែគុន្ទង ក្បាធីនោះ **[៥]** នៃ ។ ទោះអុចរោគ្គក្តី តែថ្ងៃទ្វាប៊ី្យ នេះទេិព្វប្រពៃ **[ទំព័រ ៧]** **[១]** ជុំម្ងៃស្រាកស្រាន ឥតមានទុកក្បែ ចាប័ចរ៍នោះនៃ ៈ **[២]** ចែងចប់បម្ទេះហោង ៕ ៕ ឯថ្នាំមម្រេញទាម ឱ្យ **[៣]** យកស់គូសរ៍កេរ៍ញី ឈ្មោះ(១) ឱ្យ យកតែតែសាកឯង្វ នោះ **[៤]** ឱ្យយករោមស្វាបកន្ទុយ ៈ ស្បែកឆ្អឹង ឱ្យតុតរួចស្ង **[៥]** និ៍ងប្រែងល្វ៍ ល្យានិងរហ៍ញី តាក័ទៀបតែសាក ឱ្យយក **[ទំព័រ ៨]** **គ** **[១]** ទិកត្រសក្ខផ្អូរ ១ ទិកស្ក ១ ទិកខ្ទឹ្យ ១ ផ្សំមឱ្យផិកសះហោង **[២]** ។ ថ្នាំមទាស់សរ៍សែឈ្មោ ឱ្យ យកសំម្បកខ្ទុំម ១ សម្បក **[៣]**

ក្រស្វា ១ សំម្បុកថ្កូវ ១ សំ ម្បុកជ្រួយ ១ ឱ្យស្មិហកា [៤] គ គ្នា ម្រេច ៧ គ្រាប់ខ្ទិម មេម ១ បុក
ឱ្យល្អិតតាក់ [៥] នីឯទិកអំម្តៅវខ្មោវឱ្យផិកជាហោង ៕ ឯថ្នាំមខ្ទនប៉ំតិតចុក [ទំព័រ ៩] [១] សៀតស្បួន
ស្រុតក្តី ឱ្យយកសំម្បុកពៅ ១ ជ្រូ ១ សំ ះ [២] ម្បុកក្រាប ១ សំម្បុកបង្គ្កៅ ១ សំម្បុកខ្ទិម ១ សំ
[៣] ម្បុកប៊ីសន្ទិក ១ ចិត្តមូលភ្ញើងទ្វា ២ ខ្ញីទ្វា ២ [៤] រំម្តេងទ្វា ២ ផ្លែចន្ទក្រស្នាចន្ទ ក្រវាញក្រកោ
សំម្បុក [៥] សង្កែរភ្ញើង ១ ប្ញុសស្បូវតុះក្បាលតំម្បូក ១ សំម្បុក [ទំព័រ ១០] ឃ [១] ឈើភ្ញើង ១ ឱ្យ
បុកតាក់ម្រេចខ្ទិម លាប្រនីឯទិកឃ្មុំកបន្ទុង [២] ស្រូវ ៣ ថ្ងៃផឹកជាហោង ះ ៕ នេះថ្នាំមតំម្ប៉ាវព្រាប្រតំ
[៣] ម្ប៉ាវផ្ទារតំម្បាវទូប្ច័ង ឱ្យ យកប្ញុសអង្គ្រោល ១ ទូសំ [៤] ម្បុកផង ប្ញុសបង្គ្កោវ ១ ប្ញុសកន្ធិរ
បា្រតាច ១ [៥] យកមកស្ងោទិក ៣ យកទិក ១ ផិកសះហោង ៕ ថ្នាំម [ទំព័រ ១១] [១] អន្តិកទាច
ហល ឱ្យយកបង្គ្កោវទ្វាប្ញុសសំម្បុកផង ១ [២] កាស្លាន ៧ ស្ងោផិក សះហោង ៕ ថ្នាំមខ្ទន [៣] ឱ្យ
យកផ្លែសំម្រោង ផ្លែហ ពៅខ្ញីយ ម្រេច ស្ងោផិក [៤] ជាហោង ៕ ថ្នាំមប់ ត្រូវយកមេមខ្ទិម ១
ម្រេច [៥] ១ លីងឱ្យខ្ទៅចបុកឱ្យល្អិត លាប្រនិងខ្ទាច (២) ជ្រូកលាបសះហ្វោ [ទំព័រ ១២] ង [១] ៕
ថ្នាំមប្ញុសតូង ថ្នាំមចិន ១ ឪជ្រីងវា ១ ស្ពុកស្ពោ ១ (៣) [២] ពុកឆ្នា ១ លំម្ពាន ១ ខ្ទិម ៧ កុំពីម្រេច
១ ចិប [៣] ត្រូវថ្នាំមទ្វានេះស្មើភាគគ្នា រកឆ្នាំងថ្មីស្ងោឱ្យផិក ១ [៤] ត្រណមថ្ងៃ ៧ ពុំឱ្យធ្លូតទិក លៀ
៕ នេះនិងសំម្តែ [៥] ងថ្នាំមប្ញុសតូងឃ្មុង ឱ្យយកទាលទុំម្ពុនបា ២ ក្តាត ទ្វា [ទំព័រ ១៣] [១] ២ ទុំម្ពុន
តំម្ងីង ១ ព្រះអង្គ្រោលបា ១ ពុន្ទៃបា ១ ប្ញុសអផ្តិស [២] បា ១ ភាគ្គីបា ១ ខ្ទិមសំ មពាវបា ១ ប្ញុស
អំម្ពិលបា [៣] ១ កន្ទៀងបា ១ ផ្ការបា ១ ប្ញុសសំម្បរតំម្ងីង ១ [៤] ចិត្តមូលភ្ញើងតំម្ងីង ១ ដ្ដីសរដ្ដីខ្មៅ
ដ្ដីលើងដ្ដីតែង [៥] ដ្ដីទ្វា ៥ នេះទុំម្ពុនបា ៣ នីម្ប ២ ក្រវាញតំម្ងីង ២ [ទំព័រ ១៤] ច [១] ផ្ការចន្ទ
តំម្ងីង ៤ ថ្នាំមទ្វានេះស្មិហភាគ ធ្វិហជាផងត្រាម [២] នៅទិកឃ្មុំមទុំម្ពុន ៥ នាល កបក្នុងស្រូវថ្ងៃ
៧ ទេព្វ ះ [៣] យកមកផិក ៕ ថ្នាំមនេះ ឈ្មោះសន្ធមហារាជ្ជបំម្បាត [៤] សារពេហក្សាធី តូចទុំ
១០០ ដុំពួក ប្ញុសតូង ១០០ ដុំពួក [៥] ឃ្មុំង ១០០ ដុំពួក ប្ញុសតូងស្អួយ ៥ ដុំពួក ប្ញុសតូងស្អួយ [ទំព័រ
១៥] [១] ពីមាត់ពីករ ៥ ដុំពួក ប្ញុសតូងដុះ ៥ ដំពួក ប្ញុសតូងរុំ [២] ហោក ៥ ដុំពួក ប្ញុស តូងចេញ
ឈ្មោ ៥ ដុំពួក [៣] ប្ញុសតូងស្គមតុះលេិងញរ ៥ ដុំពួកឯថ្នាំមនេះបេិហស្រី [៤] មានផ្ទៃកុំឱ្យផិកលៀ
ថ្កា បេិហព្រះស័ឃ្វ ឱ្យលាប្រនីងទិ [៥] កអំម្តៅខ្មៅផិកបានហោង ៕ នេះថ្នាំមតេចនៅកន្ទុយលិន [ទំព័រ
១៦] ឆ [១] ក្តី ប្ញុសតូងរម្យក្តីចេញទិកភ្នែកក្តី ទ្វាស្បែកក្តីភ្នែក [២] ក្រហមផ្ង់ផិតក្តី ឱ្យយក ផ្កា
ប្រលិត ១ ផ្កានួនស្រី [៣] ១ ផ្កាម្ទិះ ១ គុលទាល ១ ថ្ងិងស្មិហគ្នាបុកឱ្យល្អិត [៤] សូនជាគុល្ងិកា
ហាលថ្ងៃឱ្យ ស្ងួតតុះនិងទិកក្រូចឆ្មា ះ [៥] លាបសះហោង ។ នេះថ្នាំមប៉ំត្រូវឱ្យយកប្ញុសក្រវាញ ១
[ទំព័រ ១៧] [១] ប្ញុសផ្តោវ ១ ប្ញុសដ្តើងចាប់ ១ ប្ញុសល្ពាក់ ១ ប្ញុសសំកុង ១ [២] ប្ញុសក្ទូរបា ១ ប្ញុសពុក
ឆ្មា ១ ប្ញុសចង្កូតត្នាត ១ ប្ញ [៣] កន្ធិបា្រតាច ១ ប្ញុស លីងលក់ ១ វាលែនពែន [៤] ១ ជ្រៃក្រិម
១ បញ្ញើហ ភ្អេក ១ វាំម្ប ១ ស្ពុក [៥] ស្ពោរ ១ វាអែម ១ វាលុផ្កុញ ១ កាលផិកតេិម [ទំព័រ ១៨]
ជ [១] នោះឱ្យអតទិក ៕ ថ្នាំមក់ត្រូវខ្ញ៉ល ឱ្យយកវាលែនពែ [២] ន ១ ប្រលៅអំម្តែ ១ ទុំពួងតៃ
ខ្ទាឆ្មា ១ ះ [៣] ងបទ្វំពី ១ វាព្រីង ទុំ ១ តេិមធ្នុង ១ ះ [៤] តកពា្រ ១ ស្ងោផិក សះហោង ។

siksacakr 6khMichelFinal.qxd 28/08/2005 20:35 Page 115



ថ្នាំមបន្ទុះ [៥] គ៌គ្រីវខ្យល យកប្រផិញ ១ ស្លាបទ្នា ១ ឪដ្វា ១ [ទំព័រ ១៩] [១] រំតេងទ្វា៉ ២ ខ្វីទ្វា៉ ២ ពុន្លៃ ១ ក្រវាញជ្រូក ១ [២] កន្ទិបារ្យតាច ១ សំ ម្បុកក្រស្វា៉ ១ ខ្ទិមសរ៍ ១ [៣] បុកនីងទិកបារ្យស្រា ទិកក្រួច សេិចក៍បាន ផិកហោង [៤] ៕ នេះថ្នាំមតំម្បោវពកក្តីយ គ៌គ្រីវហេិតហតក្តីទុល ក្តី [៥] ឈេិហតេិមទ្រូងក្តី ឪ្យយកវាវ៍លែនពែន ១ បង្ក្យេីរ [ទំព័រ ២០] ឈ [១] ខ្នោតក្តី ក្តាង៍បារ្យក្តី ប្តុសដៃ្យ ក្រិម ១ វាវ៍ប្រេង ១ ប្តុស [២] លំពស ១ ពុកឆ្នាំជ្រុក ១ អង្គាបុស ១ ប្តុស [៣] ត្រមួងសីក ១ ប្តុស ព្រះព្នៅ ១ ឈេិហឯច (៤) [៤] ១ សំម្បុកស្តុកស្តោ ១ ខ្លុរ ១ ផ្ទី ១ ប្តុសម្រេះ [៥] ១ លោលំពៃ ១ ប្តុសអំម្តោព្រៃ ១ ប្តុសកន្ទោង ១ [ទំព័រ ២១] [១] ប្តុសទុន្លីងតំរី ១ ប្តុសខ្វែងពារ៍ ១ ប្តុសប្រផិញ ១ [២] ប្តុសឪដ្វា ១ សំម្បុក ឪជ្រីង ១ រំតេង ១ [៣] ថ្នាំមចិន ១ តែក ១ សំណរ៍ ១ ថ្នាំមនេះស្វោ [៤] ផិក ង្វូត ៗ ស្ងប្រេងល្ង លាបរិតសះហោង ៗ [៥] ឯថ្នាំមប្រម៉ែស ឪ្យយកប្តុសវាវ៍យោវ ១ សំម្បុកស្រម៉" ១ [ទំព័រ ២២] ញ [១] រំពាត៍ជ្រូក ១ ដុន្លូស ១ សំម្បុកវ៍ល្ងួស ១ ប្តុស [២] អន្តាតគោ ១ ក្រាង៍តី សរ៍ ១ អន្តាតស្រមុត ១ [៣] ខ្ទិមសរ៍ ១ ថ្ងូវ ១ ៖ ម្រេច ១ ខ្ទិមក្រហម ១ ៖ [៤] យកមកបុកផិកនៅទិក ត្រប៉ៃដាហោង ៗ ថ្នាំម [៥] បន្ទុះប្រម៉ៃសនោះ ឪ្យយកឈេិហខ្មៅ ១ ម្រេច ១ [ទំព័រ ២៣] [១] ផែះ ១ អង្គោម ១ ស្វោទិក ៣ យកទិក ១ បេិ [២] នោមវ៍ហា្យណោ្យ ឪ្យ យកថ្នាំមយ៉ត់នោះ ប្តុស [៣] ប្រយង ១ សំម្បុកក្រពៅ ១ ប្តុសអន្ទាញ ១ [៤] ទុំម្ទូនស្មិគ្នា ឪ្យយក ស្វោទិក ៣ យកទិក ១ [៥] ឪ្យផិកហោង ៕ នេះថ្នាំមបួសចុងចំម្ងក ឪ្យយក [ទំព័រ ២៤] ដ [១] សំម្បុកច្វា ១ ភ្នំមក្មែង ១ វាវ៍ ប្រេង ១ ព្រះរ៍ម្សៅ [២] ត ១ តុះនិងទិកបារ្យ លាបកេិតដាមុកហោង ៖ [៣] ៕ ថ្នាំមបួសក្នុងតេិមទ្រូង ៖ ឪ្យយកប្តុសភ្វាង៍ ១ ៖ [៤] ប្តុសត្រាគី្យសរ៍ ១ ៖ យកស្ទិកផងតុះនិងប្រេង [៥] រ៍ង្វេខ្មោវឪ្យលាបនោះ នីងសះហោង្វ ឯថ្នាំមបួសធុត ៗ [ទំព័រ ២៥] [១] ៗ នេះនិងស្រតីតំម្ទិរហេិត មាន ៧ ដុំពួកហៅហេិត ខ្វា ១ [២] ហេិតមាន្ទ ១ ហេិតឆ្នាំ ១ ហេិតស្វា ១ ហិ [៣] តអន្ទើក ១ ហេិត តំរីង ១ ហេិតព៍ពៃ ១ [៤] ៕ ឯហេិត ឆ្នាំ ១ ស្វា ១ ហេិតទ្វា៉ពី្យនេះ មេិល [៥] ពុំដាលេិ្យ បេិហវាហេិ្យតែងតែនីងស្វាប៉ ហោង នេះ [ទំព័រ ២៦] ឋ [១] ហៅហេិតកុំម្ទិត ៗ ឯហេិតឪ្យមេិលនោះ ៥ ហេិត [២] ខ្វារ ឪ្យយក ព្រះក្រុង ខ្មៅ ១ បន្ទូលពេជ្ញ ១ [៣] ចិតមូលក្មេិង ១ ក្រ វាញជ្រូក ១ ទងខ្ទិម ១ [៤] ផ្វៃព្នៅ ១ តេិមទាល ១ ខ្វីក្មេិង ១ ម្រេច ១ តីផ្ទី [៥] ១ ទ្វា៉ស់នេះស្មិភាគបុកផងគ្នា លា្យនិងទិកឃ្មុំ [ទំព័រ ២៧] [១] ផិកសះហោង ៗ ឯហេិតប្រលំមនីងក្អួកនោះហៅហេិ [២] តមាន្ទ យកចិតត្រមូលក្មេិង ៨ កំល្វាំក្តួច [៣] ៤ ខ្វី្យក្មេិង ២ កំល្វា៉ តីផ្ទី ១ ម្រេច ១ បុក [៤] ផងគ្នាសូនដាគុល្វិការ៍លេបសះ ហោង ៗ ឯហេ្តិ [៥] អន្ទើកឪ្យយកគុន្ទី ១ បង្គី ១ មមាញ ១ ស្វិកអំម្ពិល [ទំព័រ ២៨] ឌ [១] ១ ស្វិក សំម្បួរ ១ ផ្ទី ១ បុកឪ្យល្អិតស្មិភាគស្វោរផិក [២] សះហោង ៗ ឯហេិត តំរីឪ្យយកគ្រួសបុនគ្រាប៉ [៣] បារ្យលា្យនិងទិកក្រួចឆ្នាំ ៖ តាក់និងផ្តិលស្ពាន់ ៖ [៤] ហាលថ្ងៃលុះល្វាចឪ្យផិកហោង ៗ ក្អកផ្វាក៉ [៥] ឈាម ឪ្យយករុងលា្យនិងចិកទិកលេប ទុលក៍ត្រូវហ្វោ ៗ [ទំព័រ ២៩] [១] ៕ សិទ្ធីកាំទោះនិង យកថ្នាំម ឪ្យតីងពី្យថ្នាំមផង [២] ៗ ឯថ្ងៃអាទិត្យ៍ព្រឹកនូវ តេិម ពេញពុន្ទិហនូវ [៣] ប្តុស ថ្ងៃត្រង នូវសន្ទិ ក រ៍សៀលនូវសំម្បុក [៤] ៗ ថ្ងៃច័ន្ទ ព្រឹកនូវខ្ទិម ត្រងនូវសន្ទិក ពេញពុន្ទិ [៥] នូវប្ញ្យ

siksacakr 6khMichelFinal.qxd 28/08/2005 20:36 Page 116



*ល្ងាចនូវសំម្បក ។ ថ្ងៃ អង្គារ ព្រឹកនូវសន្និក* **[ទំព័រ ៣០] ឃ [១]** *ពេញពុន្និនូវសំម្បក ត្រូវនូវតេិម ល្ងាចនូវបុស ។ ថ្ងៃ* **[២]** *ពុទ្ធ ព្រឹកនូវបុស ពេញ ពុន្និនូវសន្និក ត្រូវនូវ* **[៣]** *សំម្បក រសៀលនូវខ្ទិម ។ ថ្ងៃព្រហស្ប ព្រឹកនូវខ្ទិម* **[៤]** *ពេញពុន្និនូវសន្និក ត្រូវ នូវបុស រសៀលនូវសំម្បក* **[៥]** *។ ថ្ងៃសុក្ក ព្រឹកនូវសន្និក ពេញពុន្និនូវបុសនិងសំម្បក ៖* **[ទំព័រ ៣១] [១]** *ត្រូវនូវសំម្បក រសៀលនូវតេិម ។ ថ្ងៃ សៅ ព្រឹក* **[២]** *នូវបុស ពេញពុន្និនូវតេិ ម ត្រូវនូវសំម្បក ៖* **[៣]** *រសៀលនូវខ្ទិម ៕៚* **[ទំព័រ ៣២] ណ**

## *សរសេរតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់ពុទ្ធសាសនបណ្ឌិត្យ*

*(គ.ស. ១៩៦៧-១៩៦៨)*

**[ទំព័រ ១]** *នេះតម្រាប់ក្បួនថ្នាំកែរោគទាំង ៤* **[ទំព័រ ២]** *[ទំព័រទទេ]* **[ទំព័រ ៣] [១]** *៙៕៚ ថ្ងៃ ១ នៅក្បាល ថ្ងៃ ២ នៅថ្ងាស ថ្ងៃ ៣ នៅច្រ-* **[២]** *មុះ ថ្ងៃ ៤ នៅមុខ ថ្ងៃ ៥ នៅពោះ ថ្ងៃ ៦* **[៣]** *នៅផ្ទៃ ថ្ងៃ ៧*(៥) *នៅអស់ទាំងខ្លួន នេះជីពចរស្រី ។* **[៤]** *ថ្ងៃ ១ ជីពចរនៅក្បាល ថ្ងៃ ២ ជីពចរនៅ* **[៥]** *អណ្ដាត ថ្ងៃ ៣ ជីពចរនៅក្រចក ថ្ងៃ ៤ ជីពចរ* **[ទំព័រ ៤] ក [១]** *នៅពោះសព្វសាច់ ថ្ងៃ ៥ ជីពចរនៅដៃ ថ្ងៃ ៦ ជីពចរ* **[២]** *នៅលឹង*(៦) *ថ្ងៃ ៧ ជីពចរនៅបាតជើង នេះឈ្មោះ* **[៣]** *ជីពចរប្រុស ។*

| | | |
|---|---|---|
| *ជីពចរនេះឯង* | *អាចារ្យសម្ដែង* **[៤]** | *ទាំងសព្វទេវា* |
| *ហៅជីពចរឆ្នាំ* | *ឲ្យចាំគ្រប់គ្នា* **[៥]** | *សព្វនៃអាត្មា* |
| | *មុខគួរឲ្យដឹង ។* | |
| *ឬរូបសព្វថ្ងៃ* | *កើត* **[ទំព័រ ៥] [១]** *ព្យាធិ៍ទីទៃ* | *ហើមហល់កន្ទួង*(៧) |
| *ជម្ងឺឈឺធ្ងន់* | *លុះ* **[២]** *ពន់ផ្សិត ។* | *ប្រើពេទ្យផងដឹង* |
| | *ឲ្យថ្នាំ*(៨) *បញ្ចុះ ។* **[៣]** | |
| *បើពេទ្យផងមើល* | *ឲ្យចៀសដំណើរ* | *នៃជីពចរ* **[៤]** *នោះ* |
| *ជីពចរនៅផ្ចិត ពោះ*(៩) | *បើគិតបញ្ចុះ* **[៥]** | *លើជីពចរនោះ* |
| | *កើតទោសពុំជា ។* | |
| *ស្មើយកថ្នាំពិស* **[ទំព័រ ៦] ខ [១]** | *មកប្រកឲ្យតស*(១០) | *ឲ្យក្សយជន្មា* |
| *ជម្ងឺរឹងធ្ងន់* | *លន់ពន់ក្ដាត់* **[២]** *ណា* | *បង្កើតទោសា* |
| | *ខុសក្រែវិញហោង ។* | |
| **[៣]** *រីថ្ងៃទាំងបី* | *ប្រហស្បតី* | *ចន្ទអង្គារផង* |
| *ប្រើឲ្យផឹក* **[៤]** *ថ្នាំ* | *បង្ខំភ្លើងផង* | *តាមដោយគន្លង* |
| | *ព្យាធិនោះ* **[៥]** *នៃ ។* | |

siksacakr 6khMichelFinal.qxd 28/08/2005 20:37 Page 117



ទោះអុជពោគក្តី តែថ្ងៃទាំងបី នេះទើបប្រពៃ
[ទំព័រ ៧] [១] ជម្ងឺស្រាកស្រាន្ត ឥតមានទុក្ខភ័យ ដីពចរនោះនៃ [២]
ចែងចប់ម្ល៉េះហោង ។

ឯថ្នាំម្រេញទាម ឲ្យ [៣] យកសត្វស-កញ្ជីឈ្មោល ឲ្យយកតែតែសាកឯង នោះ [៤] ឲ្យយករោមស្វាបកន្ទុយ ស្បែកឆ្អឹង ឲ្យដុតរួចស្ង [៥] នឹងប្រេងល្ង លាយនឹងរញ្ញី (១១) ដាក់ទៀបតែសាក ឲ្យយក [ទំព័រ ៨] គ [១] ទឹកត្រសក់ផ្អែរ ១ ទឹកស្ករ ១ ទឹកខ្ញី ១ ផ្សំឲ្យផឹកសះហោង ។ [២] ថ្នាំទាស់សរសៃឈាម ឲ្យយកសំបកក្តម្ព ១ សំបក [៣] ក្រសាំង ១ សំបកថ្កូវ ១ សំបកជ្រួយ ១ ឲ្យស្មើភាគ [៤] គ្នាម្រេច ៧ គ្រាប់ ខ្ទឹមមើម ១ បុកឲ្យល្អិតដាក់ [៥] នឹងទឹកអំពៅខ្មៅ ឲ្យផឹកជាហោង ។ ឯថ្នាំកូនប្រជិតចុក [ទំព័រ ៩] [១] សៀតស្បូនស្រុតក្តី ឲ្យយកសំបកពោធិ ១ ជ្រួយ ១ [២] សំបកក្រាយ ១ សំបកបង្កោ ១ សំបកខ្ទឹម ១ [៣] សំបកបីសន្ទឹក ១ ចិត្រមូលភ្លើងទាំង ២ ខ្ញីទាំង ២ [៤] រម្ដេងទាំង ២ ផ្លែចន្ទ ផ្កាចន្ទ ក្រវាញ ក្រកោ សំបក [៥] សង្កែភ្លើង ១ បុសស្បូវដុះក្បាលដំបូក ១ សំបក [ទំព័រ ១០] ឃ [១] ឈើភ្លើង ១ ឲ្យបុកដាក់ម្រេច ខ្ទឹម លាយនឹងទឹកឃ្មុំកប់ក្នុង [២] ស្រូវ ៣ ថ្ងៃ ផឹកជាហោង ។ នេះថ្នាំដំបៅព្រាយ [៣] ដំបៅឆា ដំបៅទាំងពួង ឲ្យយកឫសអង្កោល ១ ទាំង [៤] សំបកផង ឫសបង្កោ ១ ឫសកញ្ឆែបាយដាច ១ [៥] យកមកស្ងោរទឹក ៣ យកទឹក ១ ផឹកសះហោង ។ ថ្នាំ [ទំព័រ ១១] [១] អណ្ដើកទាចហល់ ឲ្យយកបង្កោទាំងឫសសំបកផង ១ [២] កាសស្ពាន់ ៧ ស្ងោរផឹកសះហោង ។ ថ្នាំកូន [៣] ឲ្យយកផ្លែសំរោង ផ្លែពោធិ៍ខ្ចី ម្រេច ស្ងោរផឹក [៤] ជាហោង ។ ថ្នាំប្រគ្រីវ យកមើមខ្ទឹម ១ ម្រេច [៥] ១ លីងឲ្យខ្លោច បុកឲ្យល្អិត លាយនឹងខ្លាញ់ជ្រូក លាបសះហោង ។ [ទំព័រ ១២] ង [១] ថ្នាំឫសដូង ថ្នាំចិន ១ វល្លិឪជ្រឹង ១ ស្ពុកស្ពុរ ១ [២] ពុកឆ្មា ១ លំពាន់ ១ ខ្ទឹម ៧ កំពឹស ម្រេច ១ ចឹប [៣] ឥសថ្នាំទាំងនេះស្មើភាគគ្នា រកឆ្នាំងថ្មីស្ងោរឲ្យផឹក ១ [៤] ត្រណាមថ្ងៃ ៧ ពុំឲ្យផ្លូតទឹកឡើយ ។ នេះនឹងសម្ដែង [៥] ថ្នាំឫសដូងឃ្លង់ ឲ្យយកទាល់ទម្ងន់បាទ ២ ក្តាតទាំង [ទំព័រ ១៣] [១] ២ ទម្ងន់តម្លឹង ១ ព្រះអង្កោលបាទ ១ ពន្លៃបាទ ១ ឫសអាចម៍ឆ្កែស [២] បាទ ១ ភាគ្គី (១២) បាទ ១ ខ្ទឹមសំព័របាទ ១ (១៣) ឫសអម្ពិលបាទ [៣] ១ កណ្ដៀងបាទ ១ ឆ្មាបាទ ១ ឫសសំបួរតម្លឹង ១ [៤] ចិត្រមូលភ្លើងតម្លឹង ១ ដីរស ដីរខ្មៅ ដីរលឿង ដីរដែង [៥] ដីរទាំង ៥ (១៤) នេះទម្ងន់បាទ ៣ នីមួយៗ ក្រវាញតម្លឹង ២ [ទំព័រ ១៤] ច [១] ផ្កាច័ន្ទតម្លឹង ៤ ថ្នាំទាំងនេះស្មើភាគ ធ្វើជាផង់ត្រាំ [២] នូវទឹកឃ្មុំទម្ងន់ ៥ នាល កប់ក្នុងស្រូវថ្ងៃ ៧ ទើប [៣] យកមកផឹក ។ ថ្នាំនេះ ឈ្មោះសន្ទរមហារាជបំបាត់ [៤] សារពើព្យាធិតូចធំ ១០០ ដំពួក ឫសដូង ១០០ ដំពួក [៥] ឃ្លង់ ១០០ ដំពួក ឫសដូងស្អុយ ៥ ដំពួក ឫសដូងស្អុយ [ទំព័រ ១៥] [១] ពីមាត់ពីក ៥ ដំពួក ឫសដូងដុះ ៥ ដំពួក ឫសដូងរំ- [២] ហោក ៥ ដំពួក ឫសដូងចេញឈាម ៥ ដំពួក [៣] ឫសដូងស្គមដុះឡើងញ័រ ៥ ដំពួក ឯថ្នាំនេះបើស្រី [៤] មានផ្ទៃកុំឲ្យផឹកឡើយ ថាបើព្រះសង្ឃឲ្យលាយនឹងទឹក [៥] អំពៅខ្មៅផឹកបានហោង ។ នេះថ្នាំដាច់នៅកន្ទុយលឹន [ទំព័រ ១៦] ឆ [១] ក្តី ឫសដូងរមាស់ក្តី ចេញទឹកភ្នែកក្តី ទាំងស្បែកក្តី ភ្នែក [២] ក្រហមងងឹតក្តី ឲ្យយកផ្កាព្រលិត ១ ផ្កានួនស្រី [៣] ១ ផ្កាម្លិះ ១

siksacakr 6khMichelFinal.qxd 28/08/2005 20:37 Page 118



គល់ទាល់ ១ ថ្ងឹងស្មើគ្នាបុកឲ្យល្អិត [៤] សូនជាគុលិកា ហាលថ្ងៃឲ្យស្ងួត ដុសនឹងទឹកក្រូចឆ្មារ [៥] លាបសះហោង ។ នេះថ្នាំប្រគ្រីវ ឲ្យយកឫសក្រវាញ ១ [ទំព័រ ១៧] [១] ឫសផ្ដៅ ១ ឫសដើងចាប ១ ឫសពោក់ ១ ឫសសំកុង ១ [២] ឫសក្ទូបាត ១ ឫសពុកឆ្មា ១ ឫសចង្កូតត្មាត ១ ឫស [៣] កញ្ជើបាយដាច ១ ឫសលីងល័ក្ត ១ វល្លិលែនពែន [៤] ១ ជ្រៃក្រឹម ១ បញ្ញើក្អែក ១ វល្លិមាស ១ ស្ដុក [៥] ស្ដុរ ១ វល្លិអែម ១ វល្លិអង្គញ់ ១ កាលផឹកដើម [ទំព័រ ១៨] **ង** [១] នោះឲ្យអត់ទឹក ។ ថ្នាំគគ្រីវខ្យល់ ឲ្យយកវល្លិលែនពែន [២] ១ ប្រឡៅអំពៃ ១ ទំពូងដៃខ្លាឆ្មា ១ [៣] ងប់ទាំងពីរ ១ វល្លិព្រីងធំ ១ ដើមធ្នង់ ១ [៤] ដកពាយ ១ ស្ងោរផឹក សះហោង ។ ថ្នាំបញ្ចុះ [៥] គគ្រីវខ្យល់ យកប្រផេញ ១ ស្វាបទា ១ ឪដាង ១ [ទំព័រ ១៩] [១] រំដេងទាំង ២ ខ្ញីទាំង ២ ពន្លៃ ១ ក្រវាញជ្រូក ១ [២] កញ្ជើបាយដាច ១ សំបកក្រសាំង ១ ខ្ទឹមស ១ [៣] បុកនឹងទឹកបាយស្រា ទឹកក្រូចសើចក៏បាន ផឹកហោង ។ [៤] នេះថ្នាំដំបៅពកក្ដី គគ្រីវហឹតហត់ក្ដី ទល់ក្ដី [៥] ឈើដើមទ្រូងក្ដី ឲ្យយកវល្លិលែនពែន ១ បង្អៀរ [ទំព័រ ២០] **ឈ** [១] ខ្នាត (១៥) ក្ដី ក្ដាំងបាយក្ដី ឫសជ្រៃក្រឹម ១ វល្លិប្រេង ១ ឫស [២] លំពស់ ១ ពុកឆ្មាជ្រក់ ១ អង្គារបុស្ស ១ ឫស [៣] ទ្រមូងសេក ១ ឫសព្រះធ្នៅ ១ ឈើអែម [៤] ១ សំបកស្ដុកស្ដុរ ១ ខ្ជាយ ១ ផ្ទី ១ ឫសម្រះ [៥] ១ លៅលំពៃ ១ ឫសអំពៅព្រៃ ១ ឫសកន្ទោង ១ [ទំព័រ ២១] [១] ឫសទន្ទីងដំរី ១ ឫសខ្ទៃងព័រ ១ ឫសប្រផេញ ១ [២] ឫសឪដាង ១ សំបកឪជ្រីង ១ រំដេង ១ [៣] ថ្នាំចិន ១ ដែក ១ សំណ ១ ថ្នាំនេះស្ងោរ [៤] ផឹកឆ្អូត ។ ស្ងប្រេងល្ង លាបរឹតសះហោង ។ [៥] ឯថ្នាំប្រមេះ ឲ្យយកឫសវល្លិយាវ ១ សំបកស្រម៉ ១ [ទំព័រ ២២] **ញ** [១] រំពាត់ជ្រូក ១ ជន្ទួស ១ សំបករលួស ១ ឫស [២] អណ្ដាតគោ ១ ក្រាំងដីស ១ អណ្ដាតសមុទ្រ ១ [៣] ខ្ទឹមស ១ ថ្កូវ ១ ម្រេច ១ ខ្ទឹមក្រហម ១ [៤] យកមកបុកផឹកនូវទឹកត្រប៉ែដាហោង ។ ថ្នាំ [៥] បញ្ចុះប្រមេះនោះ ឲ្យយកឈើខ្មៅ ១ ម្រេច ១ [ទំព័រ ២៣] [១] ផេះ ១ អង្កោម (១៦) ១ ស្ងោរទឹក ៣ យកទឹក ១ បើ [២] នោមរហ័សណាស់ ឲ្យយកថ្នាំឃាត់នោះ ឫស [៣] ប្រយង្គុ ១ សំបកក្រពៅ ១ ឫសអញ្ចាញ ១ [៤] ទម្ងន់ស្មើគ្នា ឲ្យយកស្ងោរទឹក ៣ យកទឹក ១ [៥] ឲ្យផឹកហោង ។ នេះថ្នាំបូសចុងចម្ពុក ឲ្យយក [ទំព័រ ២៤] **ដ** [១] សំបកចារ ១ ក្ដុំភ្លែង ១ វល្លិប្រេង ១ ព្រះរមៀត [២] ១ ដុសនឹងទឹកបាយលាបកើតជាមុខហោង ។ [៣] ថ្នាំបូសក្នុងដើមទ្រូង ឲ្យយកឫសក្ទាំង ១ [៤] ឫសក្រាំងដីស ១ យកស្ងឹកផងដុសនឹងប្រេង [៥] ល្ងខ្មៅ ឲ្យលាបនោះនឹងសះហោង ឯថ្នាំបូសធុត ។ [ទំព័រ ២៥] [១] នេះនឹងស្រដីដំណើរហឹត មាន ៧ ដំពូកហៅ ហឹតខ្លា ១ [២] ហឹតមាន់ ១ ហឹតឆ្មា ១ ហឹតស្វា ១ ហឹត [៣] អណ្ដើក ១ ហឹតដំរី ១ ហឹតពពៃ ១ ។ [៤] ឯហឹតឆ្មា ១ ស្វា ១ ហឹតទាំងពីរនេះ មើល [៥] ពុំជាឡើយ បើជាហើយតែងតែនឹងស្លាប់ហោង នេះ [ទំព័រ ២៦] **ប** [១] ហៅហឹតកំណើត ។ ឯហឹតឲ្យមើលនោះ ៥ ហឹត [២] ខ្លា ឲ្យយកព្រះក្រុងខ្មៅ ១ បណ្ដូលពេជ្រ ១ [៣] ចិត្រមូលភ្លើង ១ ក្រវាញជ្រូក ១ ទងខ្ទឹម ១ [៤] ផ្លែធ្នៅ ១ ដើមទាល់ ១ ខ្ញីភ្លើង ១ ម្រេច ១ ដីប្លី [៥] ១ ទាំងឥសនេះស្មើភាគបុកផងគ្នា លាយនឹងទឹកឃ្មុំ [ទំព័រ ២៧] [១] ផឹកសះហោង ។ ឯហឹតប្រឡំនឹងក្អកនោះ ហៅហឹត [២] មាន់ យកចិត្រមូលភ្លើង ៨ កំលាំងក្ដួច [៣] ៤ ខ្ញីភ្លើង ២ កំលាំងដីប្លី ១ ម្រេច ១ បុក [៤] ផង

siksacakr 6khMichelFinal.qxd 28/08/2005 20:38 Page 119



គ្នា សូនជាគុលិកា លេបសះហោង ។ ឯហឹត [៥] អណ្ដើកឲ្យយកកន្ទី ១ បត្តី ១ មមាញ ១ ស្ទឹក អម្ពិល [ទំព័រ ២៨] **ឍ** [១] ១ ស្ទឹកសំបួរ ១ ផ្ទី (១៧) ១ បុកឲ្យល្អិតស្មើភាគស្ងោរផឹក [២] សះហោង ។ ឯហឹតដំរី ឲ្យយកក្រួសប៉ុនគ្រាប់ [៣] បាយលាយនឹងទឹកក្រូចឆ្មា ដាក់នឹងផ្តិលស្ពាន់ [៤] ហាលថ្ងៃលុះល្ងាចឲ្យផឹកហោង ។ ក្អកផ្ទាក់ [៥] ឈាម ឲ្យយករង្គលាយនឹងចេកទឹកលេប ទល់កំត្រូវហោង ។ [ទំព័រ ២៩] [១] សិទ្ធីការ្យទោះនឹងយកថ្នាំ ឲ្យដឹងពិសថ្នាំផង ។ [២] ឯថ្ងៃអាទិត្យព្រឹកនៅដើម ពេញពន្ទឹនូវ [៣] បុស ថ្ងៃត្រង់នៅសន្ទឹក រសៀលនៅសំបក ។ [៤] ថ្ងៃចន្ទ័ ព្រឹកនៅខ្ទឹម ត្រង់នៅសន្ទឹក ពេញពន្ទឹ [៥] នៅបុស ល្ងាចនៅសំបក ។ ថ្ងៃអង្គារ ព្រឹកនៅសន្ទឹក [ទំព័រ ៣០] **ឈ** [១] ពេញពន្ទឹនៅសំបក ត្រង់នៅដើម ល្ងាចនៅបុស ។ ថ្ងៃ [២] ពុធ ព្រឹកនៅបុស ពេញពន្ទឹនៅសន្ទឹក ត្រង់នៅ [៣] សំបក រសៀលនៅខ្ទឹម ។ ថ្ងៃព្រហស្បតិ៍ ព្រឹកនៅខ្ទឹម [៤] ពេញពន្ទឹនៅសន្ទឹក ត្រង់នៅបុស រសៀលនៅសំបក ។ [៥] ថ្ងៃសុក្រ ព្រឹកនៅសន្ទឹក ពេញពន្ទឹនៅបុសនិងសំបក [ទំព័រ ៣១] [១] ត្រង់នៅសំបក រសៀលនៅដើម ។ ថ្ងៃសៅរ៍ ព្រឹក [២] នៅបុស ពេញពន្ទឹនៅដើម ត្រង់នៅសំបក [៣] រសៀលនៅខ្ទឹម ៕៚ [ទំព័រ ៣២] **ណ**

## កំណត់អត្ថន័យ

៙ យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះអ្នកស្រី ហ្សាកឹលីន ហ្វីល្លីយ៉ូហ្សាត់ ដែលបានជួយរកសាត្រាពេទ្យបុរាណ ។

(១) អ្នកចារបានចារពាក្យថា «ញីឈ្មោះ» តែគេបានគូសរះមុខចោល និងសរសេរកែ ដាក់តួ ល ជំនួស នឹងទឹកខ្មៅនៅខាងលើវិញ ។

(២) ត្រូវអាន ខ្វាញ់ វិញ ។

(៣) នៅក្នុងអត្ថបទដើម គេបានចារ៖ «ឪជ្រើងវា ១ ស្ពុកស្ពោ ១» រួចគេបានគូសខ្សែបន្ទាត់មួយដើម្បីឲ្យប្រាប់ថា ត្រូវអាន «ឪជ្រើង ១ វាស្ពុកស្ពោ ១» (ឪជ្រើង ១ វល្លិស្ពុកស្ពុរ ១) វិញ ។

(៤) ត្រូវអាន ឈើឯម វិញ ។

(៥) ថ្ងៃ ១ គឺថ្ងៃអាទិត្យ ថ្ងៃ ២ គឺថ្ងៃចន្ទ ។ល។ ដល់ថ្ងៃ ៧ គឺថ្ងៃសៅរ៍ ។

(៦) តាមវចនានុក្រមខ្មែរ ទ. ១១០៨ ពាក្យថា លឹន ជា «អង្គជាតសត្វចតុប្បាទឈ្មោល» តែនៅឯនេះជាអង្គជាតរបស់បុរស ។

(៧) នៅក្នុងអត្ថបទដើម គេបានចារ៖ "កន្ទ់ង" មិនដឹងថាត្រូវអានយ៉ាងដូចម្ដេច តែពាក្យនេះត្រូវចួននឹងចុងឃ្លាទី ៧ នៃបទខាងដើម គឺពាក្យថា "ផ្សិង" និងត្រូវចួននឹងចុងឃ្លាទី ៥ នៃបទជាមួយគ្នា គឺពាក្យថា "ដឹង" ។ ហាក់បីដូចជាពាក្យកាព្យនៅកន្លែងនេះ បានចួនយ៉ាងស្បើយ ។ សូមមើលលោក អៀង សាយ (គ.ស. ១៩៦៦: ១) ។

(៨) នៅក្នុងអត្ថបទដើម គេបានចារ៖ "ចាំ្ន" (អានថា ចាំ) រួចគេបានកែជើង ម នឹងទឹកខ្មៅ ជាជើង ន វិញ ដើម្បីឲ្យអានថា ថ្នាំ វិញ តែគេបានភ្លេចដាក់សក់តួ ថ ។

(៩) ស្មេរបានសរសេរពាក្យថា ពោះ នៅត្រង់នេះ មិនត្រូវទេ ពីព្រោះមិនចួននឹងពាក្យថា គិត ហើយ

ធ្វើឲ្យឃ្លាមានប្រាំពាក្យ ។ បើលុបពាក្យនេះចោល ត្រូវណាស់ ពីព្រោះពាក្យថា ផ្ចិត ចួននឹងពាក្យថា គិត ហើយឃ្លាមានបួនពាក្យ ។

(១០) ឥស គឺ អស់ ។

(១១) តាមលោក ម៉ឺណូត៍ (១៩៣០: ២៤-២៥) គេអាចយកក្បាលពស់វែក ឬ យកសត្វរញី ដុតឲ្យខ្លោច ហើយយកកម្ទេចសត្វទាំងពីរនេះបន្តិចបន្តួច ផ្សំនឹងថ្នាំរុក្ខជាតិបាន ។ នៅប្រទេសខ្មែរ មេផ្ទះក៏ចេះយកសត្វអង្ក្រង សំបុកកន្ត្រាំង សំបុកពីងពាង ខ្ទៅ ខ្យង ឬ ឈ្លើង មកប្រើជាថ្នាំ (សូមមើល ក្រូស្ហ្គត៍ ២០០០: ២២) ។

(១២) យើងខ្ញុំមិនដឹងថា គេបានសរសេរ "ភាគ្គី" ឬ "ភាត្តី" ពីព្រោះ គ និង ត មានរូបតួ និង ជើង ដូចគ្នា ។ ប្រហែលជាឈ្មោះដើមភគ្គី?

(១៣) ប្រហែលគួរកែជា «ខ្ទឹមបាទ ១ សំព័របាទ ១» វិញ?

(១៤) ត្រូវអាន «ដីរទាំង ៤» វិញ ។

(១៥) តាមវចនានុក្រមខ្មែរ ហៅ បន្លៀវខ្វូត ឬ កណ្តៀវខ្វូត ។

(១៦) ប្រហែលគេបានសរសេរខុស ហើយត្រូវអាន អង្កោល វិញ ។

(១៧) មិនដឹងថាត្រូវអាន ផ្ទី ឬ ផ្ទឹ ៕

## ឯកសារពិគ្រោះ


◎ ក្រូស្ហ្គត៍, ស្វាហ្ស៊ិក «[ដំណើរសះស្បើយដែលមើលមិនឃើញ ។ កំណត់ជាតិពន្ធុ-វេជ្ជវិជ្ជាក្នុងមជ្ឈដ្ឋានជនបទនៅប្រទេសកម្ពុជា] » (ជាភាសាបារាំង) ក្នុង **អាស៊ានី** លេខ ៥, មិថុនា ២០០០, ទំព័រ ១៣-៤០ ។

Crochet, Soizick, « L'invisible guérison. Notes d'ethnomédecine en milieu rural au Cambodge », *Aséanie*, 5, juin 2000, pp. 13-40.

◎ ឃីង ហុកឌី **ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ** ភ្នំពេញ, បណ្ណាគារអង្គរ, ឆ្នាំ ២០០៣ ។

◎ ឃុន សាមេន [**មគ្គុទេសក៍ថ្មីនៃសារមន្ទីរជាតិ**] (ជាភាសាអង់គ្លេស) ភ្នំពេញ, ឆ្នាំ ២០០២ ។

Khun Samen, *The New Guide of National Museum*, Phnom-Penh, 2002.

◎ ចាន់-ឱក [**ចំណែកទានដល់ការសិក្សាអំពីវិធីព្យាបាលរោគបែបបុរាណនៅប្រទេសខ្មែរ**] (ជាភាសាបារាំង) ប៉ារីស, និក្ខេបបទបញ្ចប់ថ្នាក់បណ្ឌិត (មិនបានបោះពុម្ពផ្សាយ), ឆ្នាំ ១៩៥៥ ។

Chan-Ok, *Contribution à l'étude de la thérapeutique traditionnelle au pays khmer*, Paris, thèse pour le doctorat de médecine (manuscrit), 1955.

◎ ចេកុប, ជូឌិថ ម. [**អក្សរសិល្ប៍បុរាណនៃប្រទេសកម្ពុជា ។ មគ្គុទេសក៍ដំបូង**] (ជាភាសាអង់គ្លេស) អុកស្ហ្វដ៍, រោងពុម្ពសាកលវិទ្យាល័យអុកស្ហ្វដ៍, ឆ្នាំ ១៩៩៦ ។

Jacob, Judith M., *The traditional literature of Cambodia: A preliminary guide*, Oxford, Oxford University Press, 1996.

⊙ ឆាន់ឌ្ល័រ, ដេវិឌ «[កាតព្វកិច្ចរបស់ក្រុមរាជស្មេរ ÷ អំពីអត្ថបទខ្មែរមួយសរសេរដោយដៃ ដែលគ្មានកាលបរិច្ឆេទ កាលពីសម័យអាណានិគម]» (ជាភាសាអង់គ្លេស) ក្នុង [**ប្រឈមមុខនឹងអតីតកាលរបស់កម្ពុជា ÷ បទនិពន្ធខ្លីៗ សំរាំង ឆ្នាំ ១៩៧១-១៩៩៤**] ដ. ឆាន់ឌ្ល័រ (បណ្ណាធិការ), ឈៀងហ្មៃ, ស៊ិលក៍វ៉ម្សប៊ុក្ស, ឆ្នាំ ១៩៩៦ ។

Chandler, David, "The duties of the corps of royal scribes: An undated Khmer manuscript from the colonial era," in *Facing the Cambodian past: Selected essays 1971-1994*, Chandler D. Chiang Mai, Silkworms Books, 1996.

⊙ ឆែម គាត រឹទ្ធី «[ទ្រឹស្តីខាងវិជ្ជាពេទ្យរបស់ខ្មែរ ÷ រោគវត្ថុករណ៍ និង វិធីវិនិច្ឆ័យរោគទាំងឡាយ]» (ជាភាសាបារាំង) ក្នុង **សិក្សាចក្រ** លេខ ៣ សៀមរាប ឆ្នាំ ២០០១, ទំព័រ ១២-១៥ ។

Chhem, R.K. « Les doctrines médicales khmères : Nosologie et méthodes diagnostiques », *Siksācakr*, Center for Khmer Studies, Siemreap, 3, 2001, pp. 12-15.

⊙ ជីវ តាក្វាន់ [**កំណត់ហេតុរបស់ ជីវតាក្វាន់ អំពីប្រពៃណីនៃប្រទេសកម្ពុជា**] (ជាភាសាបារាំង លោក ប៉ូល ប៉េល្លីយ៉ូត៍ ជាអ្នកបកប្រែ) ប៉ារីស, អាឌ្រីយ៉ាំង មែហ្សុនណឺវ, ឆ្នាំ ១៩៥១ ។

Tcheou Ta-Kouan, *Mémoires sur les coutumes du Cambodge de Tcheou Ta-Kouan* (Traduit par Paul Pelliot), Paris, Adrien-Maisonneuve, 1951.

⊙ ដឺ ប៊ែណុំង, អូលីវីយេ៉រ៍ «[អំពីវត្តអារាមខ្មែរ ÷ ការរៀបចំ និង និមិត្តរូបនិយម]» (ជាភាសាអង់គ្លេស) ក្នុង [**វត្តអារាមខាងព្រះពុទ្ធសាសនា**] ពីយែរ ពីស្ហារដ៍ និង ហ្វ្រង់ស្វា ឡាហ្ស៊ីរ៉ាដ៍ (បណ្ណាធិការ), ប៉ារីស, ស.ប.ច.ប.ប., ឆ្នាំ ២០០៣, ទំព័រ ២០៩-២១៨ ។

Bernon (de), Olivier, "About Khmer monasteries: Organization and symbolism", in *The Buddhist monastery*, Pierre Pichard & François Lagirarde (eds), Paris, EFEO, 2003, pp. 209-218.

⊙ ឌី ផុន **វចនានុក្រមរុក្ខជាតប្រើប្រាស់ក្នុងប្រទេសកម្ពុជា** ភ្នំពេញ ឆ្នាំ ២០០០ ។

⊙ ធាតា សុទ្ធិធម្ម «[ស្ថាបត្យកម្មវត្តអារាមក្នុងភាគឦសាននៃប្រទេសថៃ]» (ជាភាសាអង់គ្លេស) ក្នុង [**វត្តអារាមខាងព្រះពុទ្ធសាសនា**] ប៉ារីស, ស.ប.ច.ប.ប., ព. ពីស្ហារដ៍ និង ហ្វ. ឡាហ្ស៊ីរ៉ាដ (បណ្ណាធិការ), ឆ្នាំ ២០០៣ ទំព័រ ១១៩-១៣០ ។

Thada Sutthitham, "Monastic architecture in Northeastern Thailand", in *The Buddhist monastery*, Pierre Pichard & François Lagirarde (eds), Paris, EFEO, 2003, pp.119-130.

⊙ នរោត្តម ឫទ្ធារសី [**ការវិវត្តនៃវេជ្ជវិជ្ជានៅប្រទេសកម្ពុជា**] (ជាភាសាបារាំង) ប៉ារីស, អារ៉ែនេត្ត ល., ឆ្នាំ ១៩២៩ ។

Norodom Ritharasy, *L'Évolution de la médecine au Cambodge*, Paris, Arnette L., 1929.

⊙ បារ៉ូ, អា. «[អំពីអាស្រមបទនិងមជ្ឈមណ្ឌលភាវនាខ្លះៗ នៅប្រទេសកម្ពុជា]» (ជាភាសាបារាំង) ក្នុង [**ព្រឹត្តប័ត្រនៃសាលាបារាំងសែសចុងបូព៌ាប្រទេស**] លេខ ៥៦, ឆ្នាំ ១៩៦៩, ទំព័រ ១១-៥៦ ។

Bareau, A., « Quelques ermitages et centres de méditation bouddhiques au Cambodge », *BEFEO*, 56, 1969, pp. 11-56.

siksacakr 6khMichelFinal.qxd 28/08/2005 20:39 Page 122



⊙ *ប៉ាវី, អា.* [**បេសកកម្មរបស់លោក ប៉ាវ, ឥណ្ឌូចិន ឆ្នាំ ១៨៧៩_១៨៩៥៖ ភូមិសាស្ត្រនិងការធ្វើដំណើរ ភាគទី ១**] *(ជាភាសាបារាំង), ប៉ារីស, ឡឺរូ (បណ្ណាធិការ), ឆ្នាំ ១៩០១ ។*

Pavie, A., *Mission Pavie, Indochine 1879-1895: géographie et voyages I*, Paris, Leroux éditeur, 1901.

⊙ *ប៊ីហ្សូត៍, ហ្វ្រង់ស្វា* [**ផ្លូវធម្មលង្កា**] *(ជាភាសាបារាំង) ប៉ារីស, ស.ប.ច.ប.ប., ឆ្នាំ ១៩៩២ ។*

Bizot, François, *Le Chemin de Laṅkā*, Paris, EFEO, 1992.

⊙ *ប៊ីហ្សូត៍, ហ្វ្រង់ស្វា* [**ដើមល្វាមែកប្រាំ៖ ការស្រាវជ្រាវអំពីពុទ្ធសាសនាខ្មែរ**] *(ជាភាសាបារាំង) ប៉ារីស, ស.ប.ច.ប.ប., ឆ្នាំ ១៩៧៦ ។*

Bizot, François, *Le Figuier à cinq branches: recherche sur le bouddhisme khmer*, Paris, EFEO, 1976.

⊙ *បេកេទ្ទី, កាទ្រីន «[អំពីប្រពៃណីបុរាណទាក់ទងនឹងគម្ពីរសាត្រានៅប្រទេសកម្ពុជា]» (ជាភាសាបារាំង) ក្នុង* [**ការស្រាវជ្រាវថ្មីៗ អំពីប្រទេសកម្ពុជា**] *ហ្វ្រង់ស្វា ប៊ីហ្សូត៍ (បណ្ណាធិការ), ស.ប.ច.ប.ប., ឆ្នាំ ១៩៩៤, ទំព័រ ៤៧-៦១ ។*

Bechetti, Catherine, « Une ancienne tradition de manuscrits au Cambodge », in *Recherches nouvelles sur le Cambodge*, Bizot F (ed.), Paris, EFEO, 1994, pp. 47-61.

⊙ *ប៉េល្លីយ៉ូត៍, ប៉ូល «[ប្រទេសហ្វូណន]» (ជាភាសាបារាំង) ក្នុង* [**ព្រឹត្តិប័ត្រនៃ ស.ប.ច.ប.ប.**] *លេខ ៣, ឆ្នាំ ១៩០៣, ទំព័រ ២៤៨-៣០៣ ។*

Pelliot, P., « Le Fou-nan », *BEFEO*, 3, 1903, pp. 248-303.

⊙ *ប៉េល្លីយ៉ូត៍, ប៉ូល* [**កំណត់ហេតុរបស់ ជីវតាក្វាន់ អំពីប្រពៃណីនៃប្រទេសកម្ពុជា ការបកប្រែថ្មី និងអត្ថាធិប្បាយដែលមិនទាន់សម្រេច**] *(ជាភាសាបារាំង), ប៉ារីស, អាទ្រីយ៉ាំង មែហ្សុនណឺវ, ឆ្នាំ ១៩៥១ ។*

Pelliot, Paul, *Mémoires sur les coutumes du Cambodge de Tcheou Ta-Kouan, version nouvelle suivie d'un commentaire inachevé*, Paris, Adrien-Maisonneuve, 1951.

⊙ *ប្រ៊ុន, វ., និង ត. ស៊្ហូម៉ាហឺរ* [**ថ្នាំរុក្ខជាតិបុរាណនៅភាគខាងជើងនៃប្រទេសថៃ**] *(ជាភាសាអង់គ្លេស) បាងកក, វ៉ៃត៍ឡូតឹស ឆ្នាំ ១៩៩៤ ។*

Brun, V., T. Schumacher, *Traditional herbal medicine in Northern Thailand*, Bangkok, White Lotus, 1994.

⊙ *ពីស្ហារដ៍, ពីយែរ, និង ហ្វ្រង់ស្វា ឡាហ្ស៊ីរ៉ាដ៍ (បណ្ណាធិការ)* [**វត្តអារាមខាងព្រះពុទ្ធសាសនា**] *(ជាភាសាអង់គ្លេស) ប៉ារីស, ស.ប.ច.ប.ប., ឆ្នាំ ២០០៣ ។*

Pichard, Pierre, François Lagirarde (eds), *The Buddhist monastery*, Paris, EFEO, 2003.

⊙ *គូ សុជា* **ក្បួនខ្នាតខ្លះនៃសំណង់ក្នុងបរិវេណវត្តអារាម** *ភ្នំពេញ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥៤៥ គ.ស. ២០០១ ។*

⊙ *ម៉ាក់កូឡេយ៍, អ.ព. «[អត្ថបទព្យាបាល និង បច្ចេកទេសព្យាបាលក្នុងវិជ្ជាពេទ្យបុរាណរបស់ជនជាតិកោះបាលី]» (ជាភាសាអង់គ្លេស) ក្នុង* [**សង្គមវិទ្យាសាស្ត្រ និង វេជ្ជវិទ្យា**] *លេខ ២៧, ៨, ឆ្នាំ ១៩៨៨ ទំព័រ ៧៧៩-៧៨៧ ។*

siksacakr 6khMichelFinal.qxd 28/08/2005 20:40 Page 123



McCauley, A.P., “Healing texts and healing techniques in indigenous Balinese medicine”, *Soc Sci Med*, 27, 8, 1988, pp. 779-787.

៙ ម៉ាតាំង, ម៉ារី-អាឡិចសង់ឌ្រីន [**សេចក្ដីផ្ដើមអំពីជាតិពន្ធុរុក្ខសាស្ត្រនៅប្រទេសកម្ពុជា**] (ជាភាសាបារាំង), ប៉ារីស, មជ្ឈមណ្ឌលជាតិនៃការស្រាវជ្រាវវិទ្យាសាស្ត្រ / មជ្ឈមណ្ឌលស្រាវជ្រាវអំពីអាស៊ីអាគ្នេយ៍និងប្រជុំកោះនៃអាស៊ីអាគ្នេយ៍, ឆ្នាំ ១៩៧១ ។
Martin, Marie-Alexandrine, *Introduction à l’ethnobotanique du Cambodge*, Paris, CNRS/CEDRASEMI, 1971.

៙ ម៉ាតាំង, ម៉ារី-អាឡិចសង់ឌ្រីន «[គោលសំខាន់នៃវិជ្ជាពេទ្យខ្មែរបុរាណ]» (ជាភាសាបារាំង) ក្នុង **សិក្សាខ្មែរ** លេខ ៦, ប៉ារីស, ឆ្នាំ ១៩៨៣, ទំព័រ ១៣៥-១៧០ និង រូបផ្តិតពុម្ពចំនួន ៩ ។
Martin, Marie-Alexandrine, « Éléments de médecine traditionnelle khmère », *Seksa Khmer*, 6, Paris, 1983, pp. 135-170 + IX pl.

៙ ម៉ាស្ប៉ឺរ៉ូ, ហ្សក [**វេយ្យាករណ៍ភាសាខ្មែរ**] (ជាភាសាបារាំង), ប៉ារីស, ឡឺរូ (បណ្ណាធិការ), ឆ្នាំ ១៩១៥ ។
Maspero, Georges, *Grammaire de la langue khmère*, Paris, Leroux éditeur, 1915.

៙ ម៉ុលហុល្លែន្ត, ជ. [**វេជ្ជាពេទ្យ មន្តអាគម និង ខ្មោចបិសាច**] (ជាភាសាអង់គ្លេស), ខាន់បេរ៉ា, បណ្ណាល័យជាតិអូស្ត្រាលី, ឆ្នាំ ១៩៨៧ ។
Mulholland, J., *Medicine, magics and evil spirits*, Canberra, National Library of Australia, 1987.

៙ ម៉ឺណូត៍, ប. [**ធាតុពេទ្យខ្មែរ**] (ជាភាសាបារាំង), ហាណូយ, រោងពុម្ពចុងបូព៌ាប្រទេស, ឆ្នាំ ១៩៣០ ។
Menaut, B., *Matière médicale cambodgienne*, Hanoi, Imprimerie d’Extrême-Orient, 1930.

៙ រស់ វិសុទ្ធ **“វេជ្ជាពេទ្យបុរាណ” ស្ដីពីថ្នាំបុរាណ និងរបៀបព្យាបាលតាមទំនៀមទម្លាប់** ភ្នំពេញ, និក្ខេបបទបញ្ចប់បរិញ្ញាបត្រ (មិនបានបោះពុម្ពផ្សាយ), សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មហាវិទ្យាល័យបុរាណវិទ្យា, ឆ្នាំ ១៩៩៥ ។

៙ លី ធាមតេង **កំណត់ហេតុរបស់ ជីវតាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា បកប្រែផ្ទាល់ពីឯកសារដើមភាសាចិន** ភ្នំពេញ, ចាត់ចែងបកប្រែដោយ លី ធាមតេង ដោយមានជំនួយពី អ៊ឹង ឡាយ, តាំង ស៊ុយគង់ និង ម៉ា អៀង, បោះពុម្ពលើកទី ៣, ព.ស.២៥១៦ គ.ស.១៩៧៣ ។

៙ លី វូអុង «[សាស្ត្រាស្លឹករឹត]» (ជាភាសាបារាំង) ក្នុង **ប្រជុំអត្ថបទសាកលវិទ្យាល័យវិចិត្រសិល្បៈក្រុងភ្នំពេញ** លេខ ១, ឆ្នាំ ១៩៦៧, ទំព័រ ៩៧-១០៩ ។
Ly Vou-Ong, « Les manuscrits sur feuilles de latanier », *Annales de l’Université des Beaux-Arts de Phnom-Penh*, 1, 1967, pp. 97-109.

៙ លីយ៉េតារ៍, ហ្ស. [**ប្រវត្តិសាស្ត្រវេជ្ជវិទ្យានៅប្រទេសឥណ្ឌា**] (ជាភាសាបារាំង) ស្ត្រាស្បួរ, ស៊ីល្បឺរម៉ាន ហ្ស., ឆ្នាំ ១៨៥៨ ។
Lietard, G., *L’Histoire de la médecine chez les Indous*, Strasbourg, Silberman G., 1858.

siksacakr 6khMichelFinal.qxd 28/08/2005 20:40 Page 124




៙ វ៉ាន់អេស្តឺរីក, ព.វ. «[វិធីព្យាបាលរោគដោយរុក្ខជាតិនៅអាស៊ីអាគ្នេយ៍ ដើម្បីប៉ូវកម្លាំង និង ផ្តល់កម្លាំងថ្មី]» (ជាភាសាអង់គ្លេស) ក្នុង [**សង្គមវិទ្យាសាស្ត្រ និង វេជ្ជវិទ្យា**] *លេខ ២៧, ៨, ឆ្នាំ ១៩៨៨, ទំព័រ ៧៥១-៧៥៩ ។*

Van Esterik, P.V., "To strenghten and refresh: Herbal therapy in Southeast Asia", *Soc Sci Med*, 27, 8, 1988, pp. 751-759.

៙ វិដាល, ហ្ស.អឺ. [**ទេសភាពរុក្ខជាតិ និងរុក្ខជាតិទាំងឡាយនៅជ្រោយឥណ្ឌូចិន**] (ជាភាសាបារាំង) ប៉ារីស, ការបោះពុម្ពផ្សាយ កាថាឡា, ឆ្នាំ ១៩៩៧ ។

Vidal, J.-E., *Paysages végétaux et plantes dans la Péninsule indochinoise*, Paris, Éditions Karthala, 1997.

៙ វិដាល, ហ្ស.អឺ., ហ្គាប្រ៊ីយែល ម៉ារតែល និង សាវរស ឡេវិត្ស «[កំណត់ក្នុងវិស័យជាតិពន្ធុរុក្ខតាម-សាស្ត្រអំពីរុក្ខជាតិខ្លះ ដែលគេប្រើប្រាស់នៅប្រទេសកម្ពុជា]» (ជាភាសាបារាំង) ក្នុង [**ព្រឹត្តិប័ត្រនៃ ស.ប.ច.ប.ប.**] *លេខ ៥៦, ឆ្នាំ ១៩៦៩, ទំព័រ ១៧១-២៣២ និង រូបផ្តិតពុម្ព ចំនួន ៦ ។*

Vidal J.-E., G. Martel, S. Lewitz, « Notes ethnobotaniques sur quelques plantes en usage au Cambodge », *BEFEO*, tome LVI, 1969, pp. 171-232 + 6 pl.

៙ ហេដ្លេយ៍, រ៉ូប៊ឺត, រត្ន ឈឹម, និង អុក សឿម [**វចនានុក្រមខ្មែរ-អង់គ្លេសទំនើប**] កិនស៊ិងតុន (រដ្ឋម៉ែរីឡែន្ត), ឆ្នាំ ១៩៩៧ ។

Headley, R.K., Rath Chim and Ok Soeum, *Modern Cambodian-English Dictionary*, Kensington (Maryland), 1997.

៙ ហ្គូឡុំប៍, ល. «[អ្នកព្យាបាលក្នុងតួនាទីជាអ្នកកណ្តាលផ្នែកវប្បធម៌នៅភាគខាងត្បូងនៃប្រទេសថៃ]» (ជាភាសាអង់គ្លេស) ក្នុង [**សង្គមវិទ្យាសាស្ត្រ និង វេជ្ជវិទ្យា**] *លេខ ១៨, ២, ឆ្នាំ ១៩៨៤, ទំព័រ ១១១-១១៥ ។*

Golomb, L., "The curer as cultural intermediary in Southern Thailand", *Soc Sci Med*, 18, 2, 1984, pp. 111-115.

៙ ហ្គៃ, ហ្ស. [**ស្លឹករឹត និង ក្រដាស៖ សាត្រា និងក្រាំង ដែលមានរូបគំនូរ នៅប្រទេសឥណ្ឌានិងនៅអាស៊ីអាគ្នេយ៍**] (ជាភាសាអង់គ្លេស) មែលប៊ួន (អូស្ត្រាលី), វិចិត្រសាលជាតិនៃវិកតូរីយ៉ា ឆ្នាំ ១៩៨២ ។

Guy, J., *Palm-leaf and paper: Illustrated manuscripts of India and Southeast Asia*, Melbourne, National Gallery of Victoria, 1982.

៙ ក្រូស្លីយេ៉រ, ហ្សក [**ការស្រាវជ្រាវអំពីជនជាតិខ្មែរ តាមអត្ថបទ និង ប្រាសាទ តាំងពីសតវត្សដំបូង ៗ នៃគ្រិស្តសករាជ**] (ជាភាសាបារាំង) ប៉ារីស, ស្កាល៉ាមែល, ឆ្នាំ ១៩២១ ។

Groslier, Georges, *Recherche sur les Cambodgiens d'après les textes et les monuments depuis les premiers siècles de notre ère*, Paris, Challamel, 1921.

៙ ហ្វីលីយ៉ូហ្សាត់, ហ្សង់ «[ក្បួនកុមារតន្ត្ររបស់រាវណៈ និងអត្ថបទស្របគ្នារបស់ឥណ្ឌា ទីបេត៍ ចិន ខ្មែរ និង អារ៉ាប់]» (ជាភាសាបារាំងស) ក្នុង [**សៀវភៅរបស់សមាគមអាស៊ី**] *លេខ ៤, ប៉ារីស, ឆ្នាំ ១៩៣៧ ។*

Filliozat, Jean, « Le *Kumāratantra* de Rāvaṇa et les textes parallèles indien, tibetain, chinois, cambodgien et arabe », Paris, *Les Cahiers de la Société Asiatique* IV, 1937.

*◎ ឡាដឺរម៉ាន, ស., និង ព. វ៉ាន់អេស្តឺរីក «[បច្ចេកទេសព្យាបាលនៅអាស៊ីអាគ្នេយ៍÷ សេចក្ដីផ្ដើម]» (ជាភាសាអង់គ្លេស) ក្នុង* **[សង្គមវិទ្យាសាស្ត្រ និង វេជ្ជវិទ្យា]** *លេខ ២៧, ៨, ឆ្នាំ ១៩៨៨, ទំព័រ ៧៤៧-៧៥០ ។*

Laderman, C., P. Van Esterik, "Techniques of healing in Southeast Asia: Introduction", *Soc Sci Med*, 27, 8, 1988, pp. 747-750.

*◎ ឡាបារ, អា.* **[ប្រវត្តិសាស្ត្រសៀវភៅ]** *(ជាភាសាបារាំង) ប៉ារីស, រោងពុម្ពសាកលវិទ្យាល័យបារាំង, ការបោះពុម្ពផ្សាយលើកទី ៨, ឆ្នាំ ២០០១ ។*

Labarre, A., *Histoire du livre*, Paris, PUF, 8e éd., 2001.

*◎ ឡឺក្លែរ, អាដេម៉ារដ៍ «[វិជ្ជាពេទ្យនៅប្រទេសខ្មែរ]» (ជាភាសាបារាំង) ក្នុង* **[ទស្សនាវដ្ដីវិទ្យាសាស្ត្រ]** *លេខ ២, ២៣, ឆ្នាំ ១៨៩៤, ទំព័រ ៧១៥-៧២១ ។*

Leclère, Adhémard, « La médecine chez les Cambodgiens », *Revue Scientifique*, 2, 23, 1894, pp. 715-721.

*◎ ឡឺក្លែរ, អាដេម៉ារដ៍ «[កាយវិភាគសាស្ត្រនៅប្រទេសខ្មែរ]» (ជាភាសាបារាំង) ក្នុង* **[ទស្សនាវដ្ដីវិទ្យាសាស្ត្រ]** *លេខ ៤, ១, ឆ្នាំ ១៨៩៤, ទំព័រ ៣៩២-៣៩៨ ។*

Leclère, Adhémard, « L'anatomie chez les Cambodgiens », *Revue Scientifique*, 4, 1, 1894, pp. 392-398.

*◎ ឡឺក្លែរ, អាដេម៉ារដ៍ «[អំពើអំពាន់នៅប្រទេសខ្មែរ]» (ជាភាសាបារាំង) ក្នុង* **[ទស្សនាវដ្ដីវិទ្យាសាស្ត្រ]** *លេខ ៥, ភាគ ៣, ឆ្នាំ ១៨៩៥, ទំព័រ ១២៩-១៣៦ ។*

Leclère, Adhémard, « La sorcellerie chez les Cambodgiens », *Revue Scientifique*, 5, Tome 3, 1895, pp. 129-136.

*◎ ឡេវិត្ស, សាវរស, និង ប. រ៉ូល្លេ៉ត៍ «[សទ្ទានុក្រមឈ្មោះដើមឈើនិងចុល្លព្រឹក្សនៃប្រទេសកម្ពុជា]» (ជាភាសាបារាំង) ក្នុង* **[ព្រឹត្តិប័ត្រនៃ ស.ប.ច.ប.ប.]** *លេខ ៦០, ឆ្នាំ ១៩៧៣, ទំព័រ ១១៧-១៦២ ។*

Lewitz S., B. Rollet, « Lexique des noms d'arbres et d'arbustes du Cambodge », *BEFEO*, tome LX, 1973, pp. 117-162.

*◎ អូ ឈៀង* **[ចត្តុចលីមូលនិធិខ្មែរ]** *(ជាភាសាបារាំង) ប៉ារីស, រោងពុម្ពជាតិ, ឆ្នាំ ១៩៥៣ ។*

Au Chhieng, *Catalogue du fonds khmer*, Paris, Imprimerie Nationale, 1953.

*◎ អៀង សាយ* **មេកាព្យ ៗ ច្បាប់ក្បួនបង្រៀនតែងកាព្យ** *ភ្នំពេញ, បណ្ណាគារ ម៉ី-សុខ, ព.ស. ២៥០៩ គ.ស. ១៩៦៦ ។*

*◎ អាំង ជូលាន «[ការនាំមករបស់ឥណ្ឌាឲ្យវិទ្យាពេទ្យខ្មែរបុរាណ ។ ការពិនិត្យពិច័យជាដំបូង]» (ជាភាសាបារាំង) ក្នុង* **[ទស្សនាវដ្ដីសមាគមអាយុវេទប្រចាំអឺរ៉ុប]** *ភាគទី ២, រ៉ែន់បែក, ឆ្នាំ ១៩៩២, ទំព័រ ១០១-១១៤ ។*

Ang Chouléan, « Apports indiens à la médecine traditionnelle khmère. Considérations préliminaires », *Journal of the European Ayurvedic Society*, Vol. 2, Reinbeik, 1992, pp. 101-114.

Errata Siksacakr 6-d.qxd 9/6/2006 6:49 PM Page 1

## បញ្ជីកែពាក្យខុសក្នុង **សិក្សាចក្រ** លេខ ៦

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|
| ៧៦ | ១១ | *ពូលាះ* | *ពូលោះ* |
| ៨៣ | ៩ | *«្វ៉ាអេម៉ឺហៀរកំបូដហ៊ុយយ៉ាំង»* | *«ថ្វ៉ាអេម៉ឺហៀរកំបូដហ៊ុយយ៉ាំង»* |
| ៨៦ | ១ | *ការរាប់ចំនួន លើសពីមួយសែន* | *ការរាប់ចំនួន លើសពីខ្ទង់លាន* |
| ៩៩ | ១៨ | *(១) ហ្វូងពិភក្ដិជានីដាឆារ ៗ* | *(២) ហ្វូងពិភក្ដិជានីដាឆារ ៗ* |

មានការភ្លាំងភ្លាត់ត្រង់លេខរៀងកំណត់អត្ថន័យ ។ ដោយច្រឡំ មានលេខរៀង (១) ពីរដង ក្នុងភាគអំពីកំណត់អត្ថន័យនោះ ។ ចាប់តាំងពីលេខរៀង (១) លើកទី ២ លេខរៀង (២) (៣) (៤) រហូតដល់ (៦០) សូមកែឲ្យអាន (២) (៣) (៤) (៥) រហូតដល់ (៦១) វិញ (ទំព័រ ៩៩ ដល់ ១០៣) ។

| | | | |
|---|---|---|---|
| ១១៥ | ១១ | *ផ្លែចន្ទ ផ្កាចន្ទ* | *ផ្លែចាន់ ផ្កាចន្ទន៍* |

## Errata pour *Siksācakr* n° 6

| Page | Ligne | Au lieu de | Lire |
|---|---|---|---|
| 22 | 9 | les chiffres au-delà de cent mille | les chiffres au-delà des millions |
| 27 | 8 | dans un *slīṅ* il y a 4 *dhvīoeṅ* | dans un *slīṅ* il y a 2 *dhvīoeṅ* |
| 31 | n. 56, l. 3 | pāli *akṣaṇa* ou *akṣaṇā* | pāli *akkhaṇa* ou *akkhaṇā* |

## Errata for *Siksācakr* No. 6

| Page | Line | Instead of | Read |
|---|---|---|---|
| 36 | 27 | *phlae cān'* [fruits of *Illicium anisatum*] | *phlae cān'* [fruit of *Diospyros decandra*] |
| 36 | 27 | *phkā cān'* [fruits of *Diospyros decandra*] | *phkā cand(n)* [star anise, fruit of *Illicium verum*] |